# អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍



## ផែនការយុទ្ធសាស្ត្រ ២០១៨-២០២១

ធ្វើការងារដើម្បីការពារកុមារពីការរំលោភបំពាន
និងការកេងចំណេញ

# មាតិកា


| | |
|---|---|
| សាររបស់នាយកប្រតិបត្តិ | 4 |
| ១- សាវតាររបស់ អកកអ | 6 |
| ១.១- ទិដ្ឋភាពទូទៅ | 6 |
| ១.២- ប្រវត្តិរបស់ អកកអ | 7 |
| ១.៣- ការច្នៃប្រឌិតថ្មី/បទពិសោធន៍ល្អៗរបស់ អកកអ | 7 |
| ១.៤- អ្នកគាំទ្រ និងម្ចាស់ជំនួយសំខាន់ៗ | 8 |
| ២- អត្តសញ្ញាណរបស់អង្គការ | 8 |
| ២.១- ចក្ខុវិស័យរបស់ អកកអ | 8 |
| ២.២- បេសកកម្មរបស់ អកកអ | 9 |
| ២.៣- តម្លៃស្នូលរបស់ អកកអ | 9 |
| ២.៤- អ្នកទទួលផលប្រយោជន៍ / ក្រុមគោលដៅ | 9 |
| ២.៥- តំបន់គោលដៅភូមិសាស្ត្ររបស់ អកកអ | 10 |
| ៣-អភិក្រមរបស់ អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ | 13 |
| ៣.១- ការអភិវឌ្ឍជនបទចម្រុះ | 13 |
| ៣.២- អភិក្រមតាមសិទ្ធិកុមារ(CRBA) | 14 |
| ៤- ទិសដៅយុទ្ធសាស្ត្រ និងកម្មវិធីស្នូលរបស់ អកកអ | 15 |
| ៤.១- ទិដ្ឋភាពទូទៅ | 15 |

៤.២- ការអភិវឌ្ឍ និងការការពារកុមារ 15

៤.៣- ការពង្រឹងអំណាចសេដ្ឋកិច្ច 17

៤.៤- ការពង្រឹងអំណាចសង្គម 20

៤.៥- សមត្ថភាពរបស់ អកកអ 23

៥- ការអនុវត្តយុទ្ធសាស្ត្រ 28

៥.១- កម្មវិធីបច្ចុប្បន្ន 28

៥.២- ការអភិវឌ្ឍស្ថាប័ន 30

៥.៣- ការផ្តល់មូលនិធិ និងធនធាន 30

# សារនាយកប្រតិបត្តិ

ចាប់តាំងពី**អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍** (**អកកអ**) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៨ កន្លងមក **អកកអ** បានចូលរួមចំណែកគួរឱ្យកត់សម្គាល់ដើម្បីធ្វើឱ្យជីវភាពរបស់កុមារមានភាពល្អប្រសើរឡើង តាមរយៈអភិក្រមគ្រប់ជ្រុងជ្រោយរបស់ខ្លួនដើម្បីឈានទៅដល់ការអភិវឌ្ឍ។ នៅឆ្នាំ ២០១២ **អកកអ** បានចាប់ផ្តើមធ្វើការត្រួតពិនិត្យជាលក្ខណៈយុទ្ធសាស្ត្រ និងបង្កើតផែនការយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីធានាថា ស្ថាប័នមួយនេះអាចបន្តការប្តេជ្ញាចិត្តរបស់ខ្លួនទៅនឹងយុទ្ធសាស្ត្ររយៈពេលបួនឆ្នាំក្នុងគោលបំណងដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារ។ តាមរយៈការបង្កើតផែនការយុទ្ធសាស្ត្រនេះ **អកកអ** អាចពិនិត្យសាឡើងវិញនូវសមាសធាតុស្នូលរបស់អង្គការជាផ្លូវការបាន។ បន្ថែមពីលើនេះទៀត ទិសដៅយុទ្ធសាស្ត្រដែលផ្តោតយ៉ាងច្បាស់លើលទ្ធផល និងផលទទួលបានពីការជះឥទ្ធិពល ចំពោះកុមារក៏ត្រូវបានបង្កើតឡើងផងដែរ។ នៅឆ្នាំ ២០១៨ នេះ អង្គការកំពុងតែធ្វើការពិនិត្យផ្ទៀងផ្ទាត់ កែសម្រួល និងបញ្ជាក់ពីផែនការខាងលើ ជាពិសេសដើម្បីពិចារណាពីការផ្លាស់ប្តូរនៅបរិបទខាងក្រៅ និងនៅក្នុង **អកកអ** ផ្ទាល់តែម្តង។

គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលរបស់ **អកកអ** បន្តប្តេជ្ញាចិត្តក្នុងការបង្កើតគោលដៅរយៈពេលវែង (១២ឆ្នាំ) ដែលផ្តោតលើការកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារបណ្តាលមកពីការរំលោភបំពាន និងការកេងផលចំណេញ។ វារួមមានទាំងវិធានការដែលត្រូវបានកំណត់ក្នុងការបង្កើននិរន្តរភាព និងសមត្ថភាពរបស់សហគមន៍ដើម្បីការពារកុមារ។ ការពិនិត្យផ្ទៀងផ្ទាត់ផែនការយុទ្ធសាស្ត្រនឹងបង្កលក្ខណៈងាយស្រួលដល់ **អកកអ** ដើម្បីឆ្លុះបញ្ចាំងពីភាពជោគជ័យ និងបញ្ហាប្រឈមជាបន្តបន្ទាប់របស់ខ្លួន ខណៈដែលអង្គការនេះកំពុងឈានទៅរកដំណាក់កាលការងារថ្មីសំដៅកាត់បន្ថយការរំលោភបំពាន និងការកេងផលចំណេញលើកុមារ។

ផែនការនេះបានកត់ត្រាទុក និងធ្វើបច្ចុប្បន្នភាពតួនាទីបច្ចុប្បន្នរបស់សហគមន៍ដែល **អកកអ** សហការជាមួយ ព្រមទាំងតួនាទីរបស់អង្គការផងដែរ។ ការជួបប្រជុំក្រុមគោលដៅ និងការសម្ភាសចំនួន ៣៥ លើកត្រូវបានធ្វើឡើងក្នុងចំណោមសមាជិកសហគមន៍ បុគ្គលិករបស់**អកកអ** មន្ត្រីរដ្ឋាភិបាល និងក្រុមប្រឹក្សាភិបាលរបស់ **អកកអ**។ លើសពីនេះទៀត ឯកសារសំខាន់ៗមួយចំនួនបានលើកឡើងពីការធ្វើបច្ចុប្បន្នភាពចេញពីទិដ្ឋភាពថ្នាក់ជាតិ។ វាមានលក្ខណៈច្បាស់លាស់ចេញពីដំណើរការពិគ្រោះយោបល់ និងឯកសារសំខាន់ៗដែលទិសដៅយុទ្ធសាស្ត្ររួមរបស់**អកកអ** មិនគួរមានការផ្លាស់ប្តូរ។ ក៏ប៉ុន្តែ ដោយសារតែមានការផ្លាស់ប្តូរទ្រង់ទ្រាយធំក្នុងចំណោមបុគ្គលិកនៃ**អកកអ** អង្គការនេះគួរតែយកចិត្តទុកដាក់លើការត្រួតពិនិត្យសមត្ថភាពរបស់ស្ថាប័ន និងបុគ្គលិកផ្ទាល់ ក៏ដូចជាគោលនយោបាយ រចនាសម្ព័ន្ធ និងនីតិវិធី។ ផែនការថ្មីត្រូវបន្តផ្តោតលើទិសដៅអនាគត និងយុទ្ធសាស្ត្រមួយដើម្បីស្វែងរកដំណោះស្រាយមួយប្រកបដោយនិរន្តរភាព។ សមាសធាតុស្នូលនៃផែនការនេះត្រូវបានសង្ខេបឡើងតាមផ្នែកខាងក្រោមៈ

| | |
|---|---|
| ចក្ខុវិស័យ | គ្រប់កុមារទាំងអស់ត្រូវទទួលបានសុខុមាលភាពសង្គមប្រកបដោយគុណភាព និងចៀសផុតពីការរំលោភបំពានគ្រប់ទម្រង់។ |
| បេសកកម្ម | **អកកអ** មានគោលដៅកែលម្អជីវភាពរស់នៅរបស់កុមារងាយរងគ្រោះ និងកុមារដែលត្រូវបានគេរំលោភបំពាននៅប្រទេសកម្ពុជាតាមរយៈការដោះស្រាយមូលហេតុនៃភាពក្រីក្រ វិសមភាព ការរើសអើងសង្គម និងការរំលោភបំពានលើកុមារ។ |
| គុណតម្លៃ | គណនេយ្យភាព<br>តម្លាភាព<br>ការចែករំលែក<br>សាមគ្គីភាព<br>កិច្ចសហការ<br>សុចរិតភាព |
| អ្នកទទួលផល | អ្នកទទួលផលប្រយោជន៍រួមមានកុមារ និងយុវជនវ័យក្មេង ដែលកម្មវិធីបានកំណត់ថា ត្រូវជួយទំនុកបម្រុង និងគាំពារ។ លក្ខខណ្ឌដែល **អកកអ** កំណត់ថាជាអ្នកទទួលផលប្រយោជន៍ពីគម្រោងមាន៖<br>• កុមារដែលកំពុងតែរស់នៅក្នុងស្ថានភាពក្រីក្រ<br>• កុមារដែលប្រឈមមុខនឹង ឬដែលកំពុងរងការរំលោភបំពាន និង/ឬការកេងផលចំណេញ<br>    ○ ការបៀតបៀន/រំលោភបំពានផ្លូវភេទ<br>    ○ ការរំលោភបំពានលើរូបរាងកាយ និងសតិអារម្មណ៍<br>    ○ ការរំលោភបំពានលើកម្លាំងពលកម្មកុមារធ្ងន់ធ្ងរ<br>    ○ ការមិនទទួលបានការអប់រំ |
| ក្រុមគោលដៅ | **អកកអ** បានកំណត់និយមន័យក្រុមគោលដៅរបស់ខ្លួនថាជា៖<br>• កុមារ និងគ្រួសារ ព្រមទាំងភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងសហគមន៍ដែលត្រូវកែលម្អជីវភាពរស់នៅរបស់កុមារដែលងាយរងគ្រោះ/អ្នកទទួលផលប្រយោជន៍របស់ **អកកអ** ដោយផ្ទាល់<br>• អង្គការមិនមែនរដ្ឋាភិបាល និងដៃគូរដ្ឋាភិបាលដែលមានឥទ្ធិពលក្នុងការផ្លាស់ប្តូរគោលនយោបាយ។ |

## ១- សាវតាររបស់អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍

### ១.១- ទិដ្ឋភាពទូទៅ

**អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ (អកកអ)** គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលមិនបម្រើនយោបាយ មិនស្វែងរកប្រាក់ចំណេញ និងមិនពាក់ព័ន្ធនឹងសាសនាឡើយ។ អង្គការនេះគឺជាអង្គការមួយក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូចដែលយកចិត្តទុកដាក់លើកុមារ និងធ្វើសកម្មភាពនៅតំបន់ដាច់ស្រយាលនៅប្រទេសកម្ពុជា។

**អកកអ** គឺជាអង្គការដែលគ្មានសមាជិកផ្សេងទៀត និងដែលស្ថិតក្រោមការដឹកនាំរបស់នាយកប្រតិបត្តិមួយរូប។ **អកកអ** រួមមានក្រុមប្រឹក្សាភិបាលនាយក គណៈកម្មាធិការគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលិក ហើយសហការជាមួយអ្នកទទួលផលប្រយោជន៍ និងដៃគូគម្រោង។ ក្រុមប្រឹក្សាភិបាលនាយកគឺជាស្ថាប័នធ្វើការសម្រេចចិត្តខ្ពស់បំផុត និងដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រសម្រាប់អង្គការទាំងមូល។ ក្រុមប្រឹក្សាភិបាលនាយកត្រូវកោះប្រជុំយ៉ាងហោចណាស់បីលើកក្នុងមួយឆ្នាំដើម្បីធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងបញ្ហាអភិបាលកិច្ច និងយុទ្ធសាស្ត្រ។ សមាជិកក្រុមប្រឹក្សារបស់ **អកកអ** គឺជាសមាជិកជាន់ខ្ពស់មកពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិផ្សេងៗគ្នានៅប្រទេសកម្ពុជា។

**អកកអ** មានការិយាល័យចំនួនបី (ស្ថិតនៅខេត្តពោធិ៍សាត់ កំពត និងការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ)។ មានបុគ្គលិកចំនួន១៤ នាក់នៅការិយាល័យកណ្តាល និង២៧ នាក់នៅការិយាល័យប្រតិបត្តិ។

**អកកអ** កំពុងតែខិតខំប្រឹងប្រែងអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ។ សម្រាប់ព័ត៌មានលម្អិត មាននៅក្នុងផ្នែកស្តីពីទិសដៅយុទ្ធសាស្ត្រខាងក្រោម។ **អកកអ** ក៏កំពុងតែខិតខំសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ប្រទេសកម្ពុជា ឆ្នាំ ២០១៥៖ លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ សម្រេចឱ្យជាទូទៅការអប់រំមូលដ្ឋាន លើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចឱ្យស្ត្រី កាត់បន្ថយអត្រាមរណភាពកុមារ ការប្រយុទ្ធនឹងមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺផ្សេងៗ។

**អកកអ** បានជួយជ្រោមជ្រែងគ្រួសារក្រីក្របំផុតប្រហែលជា ២០០០ គ្រួសារនៅប្រទេសកម្ពុជាក្នុងមួយឆ្នាំៗ តាមរយៈអភិក្រមផ្តោតលើកុមារដែលដោះស្រាយបញ្ហាប្រឈមនានាជាច្រើន៖ កង្វះខាតការអប់រំ ប្រាក់ចំណូលគ្រួសារ ការធ្វើអន្តោប្រវេសន៍ និងការជួញដូរ ការទទួលបានទឹកស្អាត និងអនាម័យល្អ និងលទ្ធភាពចូលរួមរបស់ប្រជាពលរដ្ឋលើការសម្រេចចិត្តដែលជះឥទ្ធិពលដល់សហគមន៍របស់ពួកគេ។ **អកកអ** កំពុងខិតខំកែលម្អជីវភាពរស់នៅរបស់កុមារដោយធ្វើការផ្ទាល់ជាមួយពួកគេ និងជួយគ្រួសារ និងសហគមន៍ពួកគេឱ្យប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាពលរដ្ឋល្អ។ **អកកអ** សកម្មក្នុងការធ្វើការជាមួយយន្តការរបស់មន្ត្រីរដ្ឋាភិបាលជាច្រើន ដើម្បីកសាងសមត្ថភាពរបស់ពួកគេក្នុងការកែលម្អជីវភាពរស់នៅរបស់កុមារ និងគ្រួសារពួកគេ។ **អកកអ** ប្រើប្រាស់យន្តការដែលមានស្រាប់ ដូចជា ក្រុមជួយខ្លួនឯង និងគណៈកម្មាធិការផ្តល់អាហារូបករ

ណ៍ដើម្បីធានាឱ្យមានការចូលរួមពេញលេញនៅគ្រប់ដំណាក់កាលនៃកម្មវិធីទាំងអស់រួមមានការរៀបចំ និងការអនុវត្តតាមរយៈការវាយតម្លៃ។ អ្នកភូមិជួបប្រជុំជាមួយបុគ្គលិកជាប្រចាំដើម្បីធ្វើផែនការ និងអនុវត្តសកម្មភាព។

## ១.២- ប្រវត្តិរបស់ អកកអ

**អកកអ** ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ២០០៧ ដោយក្រុមអ្នកជំនាញខ្មែរខាងការអភិវឌ្ឍលើវិស័យអភិវឌ្ឍន៍ជនបទ និងការលើកកម្ពស់សិទ្ធិកុមារដែលមានបទសោធន៍ធ្វើការជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំ។ ចាប់តាំងពីការបង្កើតមក បុគ្គលិក និងក្រុមប្រឹក្សាភិបាលរបស់ **អកកអ** បានបង្ហាញជាបន្តបន្ទាប់ថា ខ្លួនកំពុងតែធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្រួសារដែលជួបការលំបាក និងក្រីក្រខ្លាំង។ តាមរយៈជំនួយផ្នែកបច្ចេកទេសពីអង្គការ terre des hommes Germany **អកកអ** ត្រូវបានបង្កើតឡើង និងចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃនៃប្រទេសកម្ពុជានៅខែមីនា ឆ្នាំ២០០៨។

ចាប់តាំងពី **អកកអ** ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨កន្លងមក អង្គការនេះបានអនុវត្តគម្រោងក្នុងតំបន់ដាច់ស្រយាលជាច្រើននៅប្រទេសកម្ពុជាប្រកបដោយភាពជោគជ័យគួរឱ្យកត់សម្គាល់។ បន្ទាប់ពីទទួលបានជោគជ័យលើគម្រោងសាកល្បងដំបូងនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា មានកម្មវិធីជាច្រើនត្រូវបានបង្កើតឡើងនៅក្នុងសហគមន៍ដាច់ស្រយាលនេះ។ នៅឆ្នាំ២០០៩ ប្រតិបត្តិការបានពង្រីកដល់ស្រុកភ្នំក្រវាញក្នុងខេត្តពោធិ៍សាត់។ ការិយាល័យនេះត្រូវបានបិទទ្វារវិញ បើទោះបីជាកម្មវិធីទាំងនោះកំពុងបន្តនៅក្នុងស្រុកនេះក៏ដោយ។ **អកកអ** បន្តធ្វើសកម្មភាពយ៉ាងខ្លាំងនៅខេត្តកំពត។ **អកកអ** មានកម្មវិធីនៅខេត្តកណ្តាលដោយផ្តោតលើកម្មវិធីទឹកស្អាត និងអនាម័យ (WASH)។

តាមរយៈគោលនយោបាយការពារកុមារ និងការយល់ដឹងពីសិទ្ធិកុមារ **អកកអ** ត្រូវបានទទួលស្គាល់ និងបញ្ជាក់ដោយរដ្ឋាភិបាលកម្ពុជាថាជា អង្គការសុវត្ថិភាពកុមារ (CSO) នៅខែមិថុនា ឆ្នាំ២០១២។

**អកកអ** គឺជាសមាជិកនៃអង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា (Cambodia ACTs) ដែលជាបណ្តាញអង្គការមិនមែនរដ្ឋាភិបាលដែលបានកំពុងបំពេញការងារជាពិសេសក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារនៅទូទាំងប្រទេសកម្ពុជា។

## ១.៣- ការច្នៃប្រឌិតថ្មី/បទពិសោធន៍ល្អៗរបស់ អកកអ

**អកកអ** ធ្វើការប្តេជ្ញាចិត្តយ៉ាងរឹងមាំក្នុងការកសាងសហគមន៍មួយប្រកបដោយនិរន្តរភាពដែលឱ្យតម្លៃលើសិទ្ធិកុមារ។ ដើម្បីសម្រេចទៅបាន **អកកអ** ជំរុញឱ្យមានកម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះ និងផ្តល់សិទ្ធិអំណាចក្នុងភាពជាដៃគូជាមួយអ្នកភូមិ និងរដ្ឋអំណាច។ តាមរយៈការអន្តរគមន៍ផ្សេងៗដូច្នេះ ឪពុកម្តាយ និងអាជ្ញាធរមូលដ្ឋានត្រូវបានអភិវឌ្ឍសមត្ថភាពរបស់ខ្លួនក្នុងការបំពេញតួនាទីការពារ និងថែទាំកុមារនៅក្នុងសហគមន៍។

បន្ទាប់ពីទទួលបានភាពជោគជ័យលើគម្រោងសាកល្បងដំបូងនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា មានកម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះ (IRD) ជាច្រើនត្រូវបានបង្កើតឡើង និងធ្វើសាឡើងវិញនៅ

ស្រុកភ្នំក្រវាញ នៅឆ្នាំ២០០៩។ អភិក្រមរបស់ **អកកអ** ត្រូវដោះស្រាយមូលហេតុនៃភាពក្រីក្រ បញ្ហាកង្វះជីវជាតិ បញ្ហាកង្វះទឹកស្អាត វិសមភាព និងការរើសអើងក្នុងសង្គម។ កម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះ (IRD) ត្រូវអនុវត្តឱ្យស្របតាមយុទ្ធសាស្ត្រជាតិគាំពារសង្គមចំពោះកុមារក្រីក្រ និងកុមារងាយរងគ្រោះ (២០១១-២០១៥) គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ និងផែនការយុទ្ធសាស្ត្រនៃក្រុមការងារថ្នាក់ជាតិទទួលបន្ទុកកុមារកំព្រា និងកុមារងាយរងគ្រោះ (NOVCTF) ២០១៣-២០១៨ និងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីសុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជា។

**អកកអ** មានគោលបំណងបន្តការពង្រីកគម្រោងនេះឱ្យកាន់តែទូលំទូលាយ ខណៈមានការផ្តល់មូលនិធិថ្មី។

### ១.៤- អ្នកគាំទ្រ និងម្ចាស់ជំនួយសំខាន់ៗ

**អកកអ** ស្វាគមន៍ចំពោះកិច្ចសហការចម្រុះជាមួយអ្នកគាំទ្រ និងម្ចាស់ជំនួយជាច្រើន។ ខាងក្រោមនេះគឺជាបញ្ជីម្ចាស់ជំនួយចាប់តាំងពីខែធ្នូ ឆ្នាំ២០១២៖

- Terre des hommes Germany
- Terre des Hommes Netherlands
- Lotus Outreach International
- Asian Community Trust (ACT)
- AusAID (CDF Fund)
- Australian Embassy (Direct Aid Program – DAP Fund)
- Australian Red Cross
- Australian Volunteers for International Development
- Australian Red Cross (DIAF Fund)
- European Union and Terre des Hommes Netherlands through Cambodia ACTs
- Holt International
- Lotus Outreach Australia
- Action on Poverty – formally the Australian Foundation for the Peoples of Asia and the Pacific Ltd (AFAP)
- CAFOD
- Rotary International
- Plan International

## ២- អត្តសញ្ញាណរបស់អង្គការ

### ២.១- ចក្ខុវិស័យរបស់ អកកអ៖

គ្រប់កុមារទាំងអស់ត្រូវទទួលបានសុខុមាលភាពសង្គមប្រកបដោយគុណភាព និងចៀសផុតពីការរំលោភបំពានគ្រប់ទម្រង់។

### ២.២- បេសកកម្មរបស់ អកកអ៖

**អកកអ** មានគោលដៅកែលម្អជីវភាពរស់នៅរបស់កុមារងាយរងគ្រោះ និងកុមារដែលត្រូវបានគេរំលោភបំពាននៅប្រទេសកម្ពុជាតាមរយៈការដោះស្រាយមូលហេតុនៃភាពក្រីក្រ វិសមភាព ការរើសអើងសង្គម និងការរំលោភបំពានលើកុមារ។

## ២.៣- តម្លៃស្នូលរបស់ អកកអ៖

- គណនេយ្យភាព៖ យើងបំពេញកាតព្វកិច្ចរបស់យើងចំពោះ **អកកអ** អ្នកទទួលផលប្រយោជន៍ ក្រុមគោលដៅ ដៃគូ និងសប្បុរសជន ដើម្បីប្រើប្រាស់ធនធានឱ្យបានសមស្រប និងធានាថា កម្មវិធីនេះនឹងផ្តល់ផលប្រយោជន៍ដល់សហគមន៍។
- តម្លាភាព៖ យើងផ្តល់ព័ត៌មានទាំងស្រុងក្នុងស្ថាប័ន និងដល់អ្នកទទួលផលប្រយោជន៍ ក្រុមគោលដៅ ដៃគូ និងសប្បុរសជនរបស់ **អកកអ**។
- ការចែករំលែក៖ យើងរួមគ្នាប្រើប្រាស់ព័ត៌មាន ធនធាន និងបទពិសោធន៍ល្អៗ។
- សាមគ្គីភាព៖ យើងធ្វើការពួតដៃគ្នាចាប់ពីថ្នាក់ក្រុមប្រឹក្សា បុគ្គលិក អ្នកទទួលផលប្រយោជន៍ ក្រុមគោលដៅ ដៃគូ និងសប្បុរសជនដោយមានគោលដៅរួម។
- កិច្ចសហការ៖ យើងធ្វើការជាមួយក្រុមប្រឹក្សា បុគ្គលិក អ្នកទទួលផលប្រយោជន៍ ក្រុមគោលដៅ ដៃគូ និងសប្បុរសជន និងចែករំលែកគំនិត ចំណេះដឹង ជំនាញ និងធនធាននានា។
- សុចរិតភាព៖ យើងបំពេញការងារដោយផ្អែកលើគុណតម្លៃ ជំនឿ និងគោលការណ៍ដែលយើងមាន។

## ២.៤- អ្នកទទួលផលប្រយោជន៍ / ក្រុមគោលដៅ

អ្នកទទួលផលប្រយោជន៍

អ្នកទទួលផលប្រយោជន៍រួមមានកុមារ និងយុវជនវ័យក្មេង ដែលកម្មវិធីបានកំណត់ថា ត្រូវជួយទំនុកបម្រុង និងគាំពារ។ លក្ខខណ្ឌដែល **អកកអ** កំណត់ថាជាអ្នកទទួលផលប្រយោជន៍ពីគម្រោងមាន៖

- កុមារដែលកំពុងតែរស់នៅក្នុងស្ថានភាពក្រីក្រ
- កុមារដែលប្រឈមមុខនឹង ឬដែលកំពុងរងការរំលោភបំពាន និង/ឬការកេងផលចំណេញ
    - - ការបៀតបៀន/រំលោភបំពានផ្លូវភេទ
    - - ការរំលោភបំពានលើរូបរាងកាយ និងសតិអារម្មណ៍
    - - ការរំលោភបំពានលើកម្លាំងពលកម្មកុមារធ្ងន់ធ្ងរ
    - - ការមិនទទួលបានការអប់រំ

បើទោះបីជាមានកុមារងាយរងគ្រោះច្រើនក្រុមក៏ដោយ (ដូចដែលបានកំណត់ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) **អកកអ** ត្រូវធ្វើការដើម្បីកែលម្អជីវភាពរស់នៅរបស់ក្រុមកុមារខាងលើ។ ប្រសិនបើកុមារម្នាក់ ឬច្រើននាក់ជួបប្រទះទម្រង់នៃភាពងាយរងគ្រោះ ជាក់ស្តែង ពួកគេជាកុមារកំព្រា ឬមិនមានកាយស

ម្បទាគ្រប់គ្រាន់ **អកកអ** អាចធ្វើការជាមួយពួកគេ ដោយសារតែកុមារទាំងនោះត្រូវបានកំណត់ថាកំពុងតែរស់នៅក្នុងស្ថានភាពក្រីក្រលំបាក និង/ឬប្រឈមមុខនឹង ឬកំពុងជួបប្រទះការរំលោភបំពាន ឬការកេងចំណេញ។

អនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ឱ្យនិយមន័យកុមារថា ត្រូវមានអាយុក្រោមដប់ប្រាំបីឆ្នាំ។ **អកកអ** នឹងប្រើប្រាស់និយមន័យអំពីកុមារនេះដោយផ្អែកលើអាយុរបស់ពួកគេ។

## ក្រុមគោលដៅ

ក្រុមគោលដៅត្រូវបានកំណត់ថាជាក្រុមទាំងឡាយណាដែល **អកកអ** នឹងត្រូវធ្វើការជាមួយដោយផ្ទាល់ ដើម្បីកែលម្អជីវភាពរស់នៅរបស់អ្នកទទួលផលប្រយោជន៍ឱ្យបានល្អប្រសើរឡើង។ ក្រុមគោលដៅរួមមាន អ្នកដែលត្រូវទទួលផលប្រយោជន៍ដោយផ្ទាល់ និងចូលរួមក្នុងកិច្ចអន្តរគមន៍របស់ **អកកអ**។ ក្នុងករណីខ្លះ កុមារដែលជាអ្នកទទួលផលប្រយោជន៍ក៏នឹងក្លាយជាក្រុមគោលដៅផងដែរ។ **អកកអ** បានកំណត់និយមន័យក្រុមគោលដៅរបស់ខ្លួនថាជា៖

- កុមារ និងគ្រួសារ ព្រមទាំងភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងសហគមន៍ដែលត្រូវកែលម្អជីវភាពរស់នៅរបស់កុមារដែលងាយរងគ្រោះ/អ្នកទទួលផលប្រយោជន៍របស់ **អកកអ** ដោយផ្ទាល់
- អង្គការមិនមែនរដ្ឋាភិបាល និងដៃគូរដ្ឋាភិបាលដែលមានឥទ្ធិពលក្នុងការផ្លាស់ប្តូរគោលនយោបាយ។

ដោយអនុលោមតាមគំរូអន្តរគមន៍របស់ **អកកអ** **អកកអ** ត្រូវធ្វើការជាមួយក្រុមគោលដៅធំដែលរួមមានច្រើនកម្រិត។ ជាពិសេស **អកកអ** ត្រូវធ្វើការជាមួយកុមារ និងគ្រួសារនៅក្នុងភូមិដែលមានវត្តមានរបស់ **អកកអ** ក៏ដូចជាភាគីពាក់ព័ន្ធសំខាន់ៗ (អ្នកជាប់កាតព្វកិច្ច) នៅក្នុងសហគមន៍របស់ពួកគេដែលជះឥទ្ធិពលដល់ជីវភាពរស់នៅរបស់កុមារទាំងនោះ។ **អកកអ** ក៏ត្រូវបំពេញការងារនៅកម្រិតថ្នាក់ជាតិតាមរយៈអង្គការមិនមែនរដ្ឋាភិបាល និងដៃគូរដ្ឋាភិបាលដើម្បីជះឥទ្ធិពលដល់ការផ្លាស់ប្តូរគោលនយោបាយ។ ភាគីពាក់ព័ន្ធសំខាន់ៗរួមមានជាលម្អិតដូចខាងក្រោម៖

- កុមារ៖ អ្នកទទួលផលប្រយោជន៍របស់ **អកកអ** កុមារផ្សេងទៀតដែលកំពុងតែរស់នៅក្នុងសហគមន៍ដៃគូកុមារ សិស្សអាហារូបករណ៍របស់**អកកអ** និងសិស្សសាលាផ្សេងទៀត
- គ្រួសារ៖ ឪពុកម្តាយ និងអាណាព្យាបាល សាច់ញាតិ គ្រួសារដែលកំពុងរស់នៅក្នុងស្ថានភាពក្រីក្រ
- ភូមិ៖ មេភូមិ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ អាជ្ញាធរមូលដ្ឋាន គ្រូបង្រៀន/នាយកសាលា SHG អ្នកស្ម័គ្រចិត្តសុខភាពភូមិ និងក្រុមគាំទ្រសុខភាពភូមិ (VHSG)
- ឃុំ៖ នគរបាល អង្គការមិនមែនរដ្ឋាភិបាល គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (CCWC)
- ស្រុក៖ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (WCCC) សាលាស្រុក មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការមិនមែនរដ្ឋាភិបាល

- ខេត្ត (កំពត ពោធិ៍សាត់ និងកណ្ដាល)៖ មេធាវី នគរបាល អង្គការមិនមែនរដ្ឋាភិបាល មន្ទីរសុខាភិបាល មន្ទីរអប់រំ និងមន្ទីរអភិវឌ្ឍន៍ជនបទ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (WCCC)
- ថ្នាក់ជាតិ៖ អង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា (Cambodia ACTs) ដៃគូអង្គការមិនមែនរដ្ឋាភិបាល MOSVY, CNCC, NOVCTF
- វិស័យឯកជន៖ តំណាងឧស្សាហកម្ម និងអាជីវកម្មធំៗក្នុងស្រុក

## ២.៥- តំបន់គោលដៅភូមិសាស្ត្ររបស់ អកកអ

បច្ចុប្បន្ននេះ **អកកអ** កំពុងតែប្រតិបត្តិការកម្មវិធីរបស់ខ្លួននៅក្នុងភូមិនៃស្រុកចំនួន៤ នៅទូទាំងបីខេត្ត។ សហគមន៍ទាំងនោះមានដូចខាងក្រោម៖

### ស្រុកវាលវែង ខេត្តពោធិ៍សាត់

**អកកអ** បានចាប់ផ្ដើមប្រតិបត្តិការនៅក្នុងស្រុកវាលវែងនៅដើមឆ្នាំ២០០៨។ ស្រុកនេះត្រូវបានជ្រើសរើសឡើងដោយសារតែវាមានអត្រាក្រីក្រខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា។ ស្រុកវាលវែងមានទីតាំងស្ថិតនៅតាមព្រំដែនកម្ពុជា ថៃ។ ប្រព័ន្ធផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធរបស់ស្រុកមានលក្ខណៈលំបាកខ្លាំងក្នុងការភ្ជាប់ទៅកាន់តំបន់ប្រជុំជន ហើយវាជាមូលហេតុដែលធ្វើឱ្យស្រុកនេះទទួលបានការអភិវឌ្ឍតិចតួចបំផុតនៅក្នុងប្រទេស។ ស្រុកនេះមានផ្ទៃដីយ៉ាងហោចណាស់ ៧០ ភាគរយដែលគ្របដណ្ដប់ដោយព្រៃឈើ និងមានតែ ២៥ ភាគរយប៉ុណ្ណោះដែលអាចធ្វើកសិកម្មបាន។ ដោយសារតែគ្រាប់មីនត្រូវបានបោសសម្អាត ហើយផ្លូវមានលក្ខណៈល្អប្រសើរឡើង ការកាប់ទន្ទ្រានព្រៃឈើទាំងស្របច្បាប់ និងខុសច្បាប់កំពុងតែគំរាមកំហែងដល់តំបន់ព្រៃឈើនៅទីនោះ។

កាលពីមុន ស្រុកនេះធ្លាប់ជាតំបន់សមរភូមិរវាងកងទ័ពខ្មែរក្រហម និងរដ្ឋាភិបាលរហូតដល់ឆ្នាំ ១៩៩៧។ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល គ្រាប់មីនរាប់សែនត្រូវបានគេបង្កប់នៅក្នុងតំបន់នេះដែលបានធ្វើឱ្យប្រជាពលរដ្ឋនៅស្រុកវាលវែងក្លាយជាជនរងគ្រោះ និងពិការ។

យោងតាមទិន្នន័យពីក្រសួងផែនការ ស្រុកវាលវែងមានគ្រួសារ ២៥ ភាគរយដែលក្រីក្របំផុត (គ្រួសារក្រីក្រកម្រិត ១ ID 2009) និងគ្រួសារ ២៦ ភាគរយជាគ្រួសារក្រីក្រ (កម្រិត ២)។ កង្វះខាតសេវាសុខាភិបាល និងទឹកស្អាតធ្ងន់ធ្ងរគឺជាបញ្ហាចម្បងក្នុងស្រុក។ មានប្រជាជនចំនួន ៩៦ ភាគរយកំពុងតែបរិភោគទឹកកង្វក់នៅរដូវប្រាំង (សៀវភៅទិន្នន័យស្រុកឆ្នាំ២០០៩) ហើយនៅឆ្នាំ២០១០ នៅសល់ត្រឹម៧០ភាគរយ។ ជាទូទៅ អ្នកភូមិមានដីច្រើននៅជិតទន្លេ និងព្រែកសម្រាប់ដាំដុះស្រូវ និងដំណាំផ្សេងទៀតដើម្បីផ្គត់ផ្គង់ក្នុងគ្រួសារ។ នៅឆ្នាំ ២០១៨ ការផ្ដល់ទឹកស្អាតនៅតែជាបញ្ហាប្រឈម។

ខណៈដែលផ្លូវថ្មីពីប្រទេសថៃកំពុងត្រូវបានសាងសង់ឡើងជាបន្តបន្ទាប់ ស្រុកវាលវែងកាន់តែមានភាពអ៊ូអរ។ វាមានការផ្លាស់ប្តូរច្រើនដូចជា ការហូរចូលនៃប្រជាជនថ្មី និងភ្ញៀវទេសចរ។ ការផ្លាស់ប្តូរទាំងនេះក៏នឹងអាចបង្កឱ្យមានហានិភ័យដល់កុមារផងដែរ។

## ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

នៅឆ្នាំ២០០៩ **អកកអ** បានបើកការិយាល័យនៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ការិយាល័យនេះបានបិទទៅវិញនៅឆ្នាំ២០១៧ ដោយសារតែបញ្ហាមូលនិធិ។ ក៏ប៉ុន្តែ **អកកអ** នៅតែបន្តអនុវត្តកម្មវិធីនៅក្នុងស្រុកនេះដដែរ។ ស្រុកភ្នំក្រវាញមាន ៧ ឃុំ និង ៥៣ភូមិ។ ដូចនៅស្រុកវាលវែងដែរ ស្រុកនេះគឺជាតំបន់ភ្នំដាច់ស្រយាលដែលមានមនុស្សរស់នៅតិចតួច និងមានគ្រាប់មីនមិនទាន់ផ្ទុះច្រើន (ពីមុនកាន់កាប់ដោយពួកខ្មែរក្រហម)។

នៅភាគខាងត្បូងនៃស្រុកនេះគ្មានប្រជាជនរស់នៅទេ ហើយមានផ្លូវតិចតួចបំផុត។ វាសម្បូរទៅដោយដើមក្រវាញជាច្រើន។ ស្រុកនេះមានទំហំធំ តែមានប្រជាជនរស់នៅតិចតួចបំផុតក្នុងកម្រិតដង់ស៊ីតេ ១៥ នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា។ ស្រុកនេះភាគច្រើនគ្របដណ្តប់ដោយព្រៃឈើ និងភ្នំ ហើយកន្លែងខ្លះទៀតសម្បូរដោយគ្រាប់មីនមិនទាន់ផ្ទុះជាពិសេសក្នុងឃុំផ្ទះរូងជិតទីរួមស្រុក។

ប្រជាជនប្រមាណជា ៧០ ភាគរយបរិភោគទឹកកង្វក់ក្នុងរដូវប្រាំង ហើយមានប្រជាជន ៩៣ ភាគរយគ្មានបង្គន់អនាម័យប្រើប្រាស់ ដែលជាហេតុបង្កឱ្យមានការបំពុលទឹកភ្លៀងធម្មជាតិទៅក្នុងអាងស្តុកទឹក និងបង្កើតឱ្យមានជំងឺចេញពីប្រភពទឹក។ ជាមធ្យម មានអ្នកភូមិប្រហែលជា ១ ភាគ ៣ បន្តចំណាយប្រាក់លើការថែទាំសុខភាពរបស់ខ្លួន។

ជាទូទៅ ភាពក្រីក្រនៅក្នុងតំបន់នេះបណ្តាលមកពីផលិតភាពកសិកម្មទាប កង្វះគ្រាប់ពូជ និងឧបករណ៍កសិកម្ម ចំណេះដឹងបច្ចេកទេសកសិកម្មនៅមានកម្រិត កង្វះខាតឥណទានសមរម្យ និងភាពគ្មានការងារធ្វើ។ អ្នកភូមិជាច្រើននាក់ប្រកបរបរចិញ្ចឹមជីវិតតាមរយៈការស្វែងរកអាហារក្នុងព្រៃ ការកាប់ទន្រ្ទានព្រៃឈើខុសច្បាប់ បរបាញ់សត្វព្រៃ ការកាប់បំផ្លាញព្រៃឈើដើម្បីធ្វើកសិកម្មដែលប៉ះពាល់ដល់បរិស្ថានធ្ងន់ធ្ងរ និងបង្កើនហានិភ័យនៃជំងឺគ្រុនឈាម/គ្រុនចាញ់ និងរងរបួស/ស្លាប់ដោយសារសំណល់មិនទាន់ផ្ទុះ។

តំបន់នេះក៏មានអត្រាចុះឈ្មោះចូលរៀនទាបដោយសារតែកង្វះខាតសាលារៀន និងផ្លូវធ្វើដំណើរវែងឆ្ងាយ ជីវភាពរស់នៅរបស់គ្រួសារខ្សត់ខ្សោយ និងគុណភាពអប់រំនៅមានកម្រិត។ បើទោះបីជាការចូលរៀននៅបឋមសិក្សាមានលក្ខណៈល្អប្រសើរឡើងក៏ដោយ ក៏អត្រាសិស្សបន្តទៅថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យនៅមានកម្រិតទាបនៅឡើយ។ នេះគឺជាលក្ខណៈពិសេសក្នុងខេត្តពោធិ៍សាត់ ដែលបានកំណត់គោលដៅដោយ **អកកអ**។

**ស្រុកឈូក ខេត្តកំពត**

ការិយាល័យទីបួនរបស់ **អកកអ** ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ២០១២ ក្នុងស្រុកឈូក ខេត្តកំពត។ តំបន់នេះត្រូវបានជ្រើសរើសឡើងដោយសារតែខ្វះអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងតំបន់ គម្លាតសេវារដ្ឋ អត្រាក្រីក្រខ្ពស់ និងកង្វះខាតសេវាសុខាភិបាល និងអនាម័យ និងបញ្ហាកម្លាំងពលកម្មកុមារ និងការធ្វើអន្តោប្រវេសន៍។ កាលពីមុន ស្រុកឈូកធ្លាប់ស្ថិតក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម។ នៅក្នុងតំបន់នេះ កុមារក្រោមអាយុ១៨ឆ្នាំមានចំនួន ៤១ ភាគរយនៃចំនួនប្រជាជនសរុប។

ឃុំដែលក្រីក្រ និងដាច់ស្រយាលបំផុត (ឃុំតាកែន និងត្រពាំងភ្លាំង) នៃស្រុកឈូកកំពុងតែជួបប្រទះអត្រាការចូលរៀនទាប ការចំណាយច្រើនតាមគ្រួសារលើការថែទាំសុខភាព និងការទិញវត្ថុធាតុដើមកសិកម្ម ហើយមានគ្រួសារចំនួន ៣៨,៤ ភាគរយ (តាកែន) និង ៣០ភាគរយ (ត្រពាំងភ្លៀង) ត្រូវបានចាត់ទុកថាមានជីវភាពក្រីក្រ។ នៅក្នុងភូមិមួយចំនួន គ្រួសារជាង៥០ភាគរយមានជីវភាពក្រីក្រកម្រិត ១ ឬ ២។

ស្រុកឈូក សម្បូរទៅដោយជម្លោះដីធ្លី និងមានការចាប់អារម្មណ៍ពីអង្គការគាំពារនានា។

**ខេត្តកណ្ដាល**

**អកកអ** យកចិត្តទុកដាក់លើកម្មវិធីទឹកស្អាត និងអនាម័យ (WASH) នៅខេត្តកណ្ដាល ដោយធ្វើការយ៉ាងជិតស្និទ្ធិជាមួយសាលារៀន និងសហគមន៍ដែលបានជ្រើសរើស។ **អកកអ** ក៏សហការជាមួយក្រុមប្រឹក្សាឃុំ ភូមិ និងសាលារៀនដើម្បីផ្សព្វផ្សាយពីសុខភាព និងអនាម័យ និងការបែងចែកទឹកស្អាត និងបង្គន់អនាម័យ។

## ៣-អភិក្រមរបស់ អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍

### ៣.១- ការអភិវឌ្ឍជនបទចម្រុះ

ការអភិវឌ្ឍជនបទចម្រុះគឺជាវិធីសាស្ត្រមួយក្នុងការធ្វើការជាមួយសហគមន៍។ វាគឺជាកម្មវិធីមួយដែលធ្វើការផ្ដោតលើការធ្វើការបញ្ចូលគ្នារវាងវិស័យផ្សេងៗ ជាជាងធ្វើតែតាមបែបប្រពៃណីតែមួយវិស័យ សកម្មភាពបញ្ចូលគ្នាដែលរួមមានសុខភាព ការអប់រំ និងកសិកម្ម។ ទស្សនទាននៃអភិក្រមចម្រុះសំដៅមិនត្រឹមតែលើពហុវិស័យប៉ុណ្ណោះទេ ក៏ប៉ុន្តែវាសំដៅដល់ភាគីពាក់ព័ន្ធជាច្រើន។ ភាគីពាក់ព័ន្ធរួមមានអ្នកទទួលផលប្រយោជន៍ (ចំពោះ **អកកអ** មានកុមារងាយរងគ្រោះជាដើម) គ្រួសារ វិស័យឯកជន សមាជិកសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អាជ្ញាធរមូលដ្ឋាន និងអ្នកផ្ដល់សេវាសុខាភិបាល និងអប់រំ។ ជាការពិតណាស់ បញ្ហាប្រឈមគឺត្រូវសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងដើម្បីឱ្យភាគីទាំងនោះអាចបំពេញឱ្យគ្នាទៅវិញទៅមកបាន និងដោយគ្មានការខ្វែងគំនិតគ្នា។ អភិក្រមនេះត្រូវផ្ដោតលើការបង្ការតាមរយៈការយកចិត្តទុកដាក់លើការដោះស្រាយមូលហេតុនៃភាពក្រីក្រ និងបញ្ហាសង្គមផ្សេងៗទៀត។

គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (MDG) ប្រាំពីរដំបូងគឺច្បាស់ណាស់ត្រូវពឹងផ្អែកលើអភិក្រមចម្រុះក្នុងការអភិវឌ្ឍ។ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ទីប្រាំបី (ដែលផ្តោតលើកំណើននៃភាពជាដៃគូសាកលសម្រាប់ការអភិវឌ្ឍ) ក៏ពឹងផ្អែកលើអភិក្រមចម្រុះក្នុងការអភិវឌ្ឍផងដែរ ហើយលើកនេះ វាពាក់ព័ន្ធនឹងការពង្រឹងការផ្លាស់ប្តូរ។ (យោង៖ de Janvry, 2015)

យុទ្ធសាស្ត្រពហុវិស័យ និងកម្រិតនៃអន្តរគមន៍របស់ **អកកអ** ត្រូវស្របតាមអភិក្រមអភិវឌ្ឍន៍ជនបទចម្រុះ។ ក្នុងរយៈពេលប្រាំឆ្នាំបន្ទាប់ អង្គការនឹងបន្តធ្វើការជាមួយកុមារ គ្រួសារ និងភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីអនុវត្តយុទ្ធសាស្ត្រជាច្រើន សំដៅបន្តដោះស្រាយភាពងាយរងគ្រោះរបស់កុមារ។ ដូចបានកំណត់ក្នុងទិសដៅយុទ្ធសាស្ត្រ **អកកអ** នឹងធ្វើការលើកិច្ចការពារកុមារ ការអប់រំ សុខាភិបាល និងកសិកម្មដោយសហការជាមួយរដ្ឋាភិបាល និងវិស័យឯកជន។

## ៣.២- អភិក្រមតាមសិទ្ធិកុមារ(CRBA)

អភិក្រមតាមសិទ្ធិកុមារ (CRBA) ត្រូវផ្អែកលើក្របខ័ណ្ឌអភិវឌ្ឍន៍ដែលត្រូវភ្ជាប់ជាមួយនឹងអភិក្រមតាមសិទ្ធិមនុស្សដែលត្រូវអនុវត្តយ៉ាងជាក់លាក់ចំពោះកុមារ។ អភិក្រមនេះត្រូវយោងទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារដែលជាគោលការណ៍ណែនាំគ្រឹះ។ គោលការណ៍ទាំងនេះរួមមានក្នុងកម្មវិធីណែនាំ គោលនយោបាយ និងការឆ្លើយតបរបស់ UNCRC ចំពោះកុមារ។ សិទ្ធិទាំងបួន (ដែលបានកំណត់ដោយ UNICEF) មាន៖

១- សិទ្ធិរស់រាន និងសុខភាព
២- សិទ្ធិទទួលបានការអប់រំ
៣- សិទ្ធិទទួលការការពារ និងការថែទាំ
៤- សិទ្ធិចូលរួមបញ្ចេញមតិ

អភិក្រម CRBA ផ្តល់អាទិភាពដល់កុមារដែលជាក្រុមងាយរងគ្រោះបំផុតដោយសារតែការរំលោភបំពានសិទ្ធិមនុស្ស។ អន្តរគមន៍នេះផ្តោតលើមូលហេតុចម្បងនៃភាពក្រីក្រ ភាពខ្វះខាត និងការរំលោភបំពានសិទ្ធិមនុស្ស។ CRBA ផ្តោតសំខាន់លើគណនេយ្យភាពនៃការទទួលខុសត្រូវ និងភាពជាសាកល និងភាពមិនអាចដាច់ពីគ្នាបាននៃសិទ្ធិទាំងអស់។ ការចងក្រងបណ្តាញ និងការទាមទាត្រូវបានចាត់ទុកថាជាសកម្មភាពសំខាន់។ សកម្មភាពទំនាក់ទំនងសាធារណៈក៏ជាផ្នែកមួយនៃយុទ្ធសាស្ត្រពង្រឹងការអនុវត្តសិទ្ធិកុមារគ្រប់ជ្រុងជ្រោយ។ គម្រោងត្រូវបានគេមើលឃើញថាជាវិធីសាស្ត្រមួយក្នុងការការពារ លើកកម្ពស់ និងពង្រឹងសិទ្ធិរបស់កុមារ។ ការផ្តល់សិទ្ធិអំណាចដល់កុមារគឺជាសមាសធាតុសំខាន់នៃអភិក្រមនេះ។ (មើលសន្ទានុក្រមសម្រាប់ការពន្យល់បន្ថែមពាក់ព័ន្ធនឹងការស្វែងអំពីការផ្តល់សិទ្ធិអំណាចរបស់ **អកកអ**) ពេលខ្លះ អភិក្រម CBRA ត្រូវបានសំដៅលើអភិក្រមអភិវឌ្ឍន៍ផ្តោតលើកុមារជាគោលដៅសំខាន់។

តាមរយៈការអនុវត្តគោលដៅកម្មវិធីយុទ្ធសាស្ត្រទាំង ៣ **អកកអ** នឹងអនុវត្ត CRBA។ សកម្មភាពសំខាន់នឹងរួមបញ្ចូលទាំង៖ ធ្វើការជាមួយកុមារ និងគ្រួសារដែលងាយរងគ្រោះបំផុតនៅក្នុងសហគមន៍នីមួយៗ

គាំទ្រដល់ការអនុវត្តសិទ្ធិកុមារ កសាងសមត្ថភាពរបស់អ្នកជាប់កាតព្វកិច្ច (ឪពុកម្តាយ អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវាអប់រំ និងសុខភាព) ដើម្បីអនុវត្តតួនាទីរបស់ខ្លួនក្នុងការការពារសិទ្ធិកុមារ និងផ្តល់សេវាដែលពួកគេត្រូវការជាចាំបាច់ បង្កើតឱកាសដល់កុមារឱ្យចូលរួមធ្វើការសម្រេចចិត្តដែលជះឥទ្ធិពលដល់ជីវភាពរស់នៅរបស់ពួកគេ ធ្វើឱ្យការទទួលបានការអប់រំមានលក្ខណៈល្អប្រសើរឡើង។

## ៤- ទិសដៅយុទ្ធសាស្រ្ត និងកម្មវិធីស្នូលរបស់ អកកអ

### ៤.១- ទិដ្ឋភាពទូទៅ

ការពិនិត្យឡើងវិញលើយុទ្ធសាស្រ្តបានផ្តល់ឱ្យ **អកកអ** នូវឱកាសមួយក្នុងការកែសម្រួលកម្មវិធីស្នូលរបស់ខ្លួន។ **អកកអ** នឹងបន្តធ្វើសកម្មភាពស្រដៀងគ្នាមួយចំនួន។ ផែនការនេះមានរយៈពេលប្រាំឆ្នាំ។ ឆ្នាំទី១ (២០១៩) គឺជាដំណាក់កាលរួមបញ្ចូលគ្នា។ សកម្មភាពទាំងនេះរួមមាន៖ ការសម្រេចឱ្យបាននូវផែនការអនុវត្តន៍ និងការកសាងសមត្ថភាពរបស់ **អកកអ** ដើម្បីបន្តអនុវត្តទិសដៅយុទ្ធសាស្រ្ត។ ៤ ឆ្នាំបន្ទាប់មកទៀតគឺជាការអនុវត្តទិសដៅយុទ្ធសាស្រ្តរបស់អង្គការ។ កម្មវិធីដែលត្រូវអនុវត្តសាឡើងវិញត្រូវស្របតាមគោលដៅកម្មវិធីយុទ្ធសាស្រ្តទាំងបី និងបន្តផែនការយុទ្ធសាស្រ្តមុន។ លើសពីនេះទៀត គោលដៅយុទ្ធសាស្រ្តមួយត្រូវជាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍរបស់អង្គការ ដោយគាំទ្រដល់គោលដៅកម្មវិធី។

### ៤.២- ការអភិវឌ្ឍ និងការការពារកុមារ

### សិទ្ធិ និងបញ្ហាដែលបានដោះស្រាយ

កុមារមួយចំនួនធំកំពុងតែជួបប្រទះនឹងការប្រើប្រាស់អំពើហិង្សា ការរំលោភបំពាន និងការកេងផលចំណេញនៅក្នុងតំបន់គោលដៅរបស់ **អកកអ** ។ អង្គការក្នុងស្រុកជាច្រើនកំពុងដោះស្រាយបញ្ហានេះ ក៏ប៉ុន្តែអាជ្ញាធរមូលដ្ឋានកំពុងតែជួបការលំបាកក្នុងការបំពេញតួនាទីរបស់ខ្លួនក្នុងនាមជាអ្នកជាប់កាតព្វកិច្ច។

គោលដៅយុទ្ធសាស្រ្តស្តីពីការអភិវឌ្ឍ និងការការពារកុមារត្រូវធ្វើឡើងស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារដែលទាក់ទងនឹងការការពារ និងការអប់រំកុមារ។

### គោលដៅទី ១៖ ធានាថា កុមារត្រូវទទួលបានការអប់រំ ការការពារ និងការថែទាំ

### គោលបំណង៖

១.១ ពង្រឹងសមត្ថភាពរបស់កុមារ និងអ្នកជាប់កាតព្វកិច្ចដើម្បីការពារ និងថែទាំកុមារ
១.២ កែលម្អ និងពង្រឹងយន្តការ និងកិច្ចការការពារកុមារ
១.៣ បង្កើនចំណេះដឹង និងជំនាញរបស់កុមារដើម្បីជំរុញដល់ការអភិវឌ្ឍកុមារ

### សកម្មភាពសំខាន់ៗ៖

១.១ ពង្រឹងសមត្ថភាពរបស់កុមារ និងអ្នកជាប់កាតព្វកិច្ចដើម្បីការពារ និងថែទាំកុមារ

១.១.១ អនុវត្តការលើកកម្ពស់ការយល់ដឹង និងការអប់រំអំពីការការពារកុមារដល់កុមារ និងគ្រួសារដែលងាយរងគ្រោះ ដូចជាកម្មវិធីមិត្តអប់រំមិត្តនៅតាមសាលារៀន និងសហគមន៍

១.១.២ ផ្តល់ការបណ្តុះបណ្តាល ប្រឹក្សាយោបល់ និងគាំទ្រដល់អាជ្ញាធរមូលដ្ឋាន CCWC និង WCCC ដើម្បីកែលម្អសមត្ថភាពរបស់ពួកគេក្នុងនាមជាអ្នកជាប់កាតព្វកិច្ច

១.២ កែលម្អ និងពង្រឹងយន្តការ និងកិច្ចការការពារកុមារ

១.២.១ សហការជាមួយភាគីរដ្ឋាភិបាល និងដៃគូអង្គការសង្គមស៊ីវិលសំខាន់ៗដើម្បីកំណត់ និងតាមដានកុមារដែលងាយរងគ្រោះ និងសម្របសម្រួលការងារពាក់ព័ន្ធនឹងកិច្ចការផ្លូវច្បាប់ និងការគាំទ្រផ្សេងៗ

១.២.២ សម្របសម្រួលកិច្ចសហការរវាងកុមារ/គ្រួសារ និងអ្នកជាប់កាតព្វកិច្ចដើម្បីរួមគ្នាបង្កើតឱ្យមានមធ្យោបាយក្នុងការទទួលបានកិច្ចការពារ និងគាំទ្រកុមារប្រកបដោយប្រសិទ្ធភាព

១.២.៣ អនុវត្តផែនការ និងការឆ្លើយតបពាក់ព័ន្ធនឹងការការពារសង្គមដ៏សមស្របដល់កុមារ និងគ្រួសារដែលកំពុងជួបវិបត្តិ ដូចជាភាពអាសន្ន ឬគ្រោះថ្នាក់

១.៣ បង្កើនចំណេះដឹង និងជំនាញរបស់កុមារដើម្បីជំរុញដល់ការអភិវឌ្ឍកុមារ

១.៣.១ ពិនិត្យឡើងវិញ និងអនុវត្តការផ្លាស់ប្តូរលើកម្មវិធីផ្តល់អាហារូបករណ៍អប់រំរបស់ **អកកអ** ដោយស្របតាមតម្រូវការរបស់សហគមន៍ និងទិសដៅយុទ្ធសាស្រ្តរបស់ **អកកអ**

១.៣.២ សហការជាមួយសហគមន៍ រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដើម្បីលើកកម្ពស់ការយល់ដឹង និងឱកាសអំពីការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ

១.៣.៣ផ្តល់ឱកាសដល់សិស្សានុសិស្សទាំងអស់ឱ្យចូលរួមក្នុងការធ្វើផែនការអនាគត និងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈ

១.៣.៤ សម្របសម្រួលដល់ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានសមស្របដល់សាលាកុមារមេត្រី និងមត្តេយ្យសិក្សា

១.៣.៥ ពិនិត្យឡើងវិញលើលក្ខខណ្ឌជ្រើសរើសសិស្សក្រីក្រតាមលក្ខខណ្ឌរដ្ឋដែលបានកែប្រែ

១.៣.៦ ធ្វើផែនការ និងរៀបចំសំណើស្វែងរកមូលនិធិដើម្បីគាំទ្រកុមារីឱ្យបន្តការសិក្សាពីបឋមសិក្សាដល់អនុវិទ្យាល័យ និងវិទ្យាល័យ។ កម្មវិធីនេរួមមានរថយន្តដឹកសិស្ស ឬកន្លែងស្នាក់នៅសមស្របសម្រាប់សិស្ស។

## លទ្ធផលដែលបានព្រាងទុក

លទ្ធផលរយៈពេលវែង៖ កុមារទទួលបានការអប់រំ ការការពារ និងការថែទាំល្អប្រសើរជាងមុន

## លទ្ធផលសំខាន់ៗ –

- សមត្ថភាពរបស់កុមារ និងអ្នកជាប់កាតព្វកិច្ចក្នុងការការពារ និងថែទាំកុមារមានភាពល្អប្រសើរជាងមុន
- យន្តការ និងកិច្ចការពារកុមារត្រូវបានពង្រឹង និងកែលម្អក្នុងការការពារកុមារ

- កុមារទទួលបានចំណេះដឹង និងជំនាញក្នុងការលើកកម្ពស់ការអភិវឌ្ឍកុមារ

### ភ័ស្តុតាងនៃការផ្លាស់ប្តូរ - សូចនាករ

| គោលដៅ | សូចនាកររយៈពេល ៣ ឆ្នាំ |
|---|---|
| កុមារ | ១. % កុមារគោលដៅដែលដឹងពីកន្លែង និងវិធីសាស្ត្រក្នុងការរាយការណ៍អំពីការរំលោភបំពានលើការការពារ<br>២. % កុមារដែលងាយរងគ្រោះក្នុងបញ្ជី OVC ដែលទទួលបានការគាំទ្រ (បែងចែកតាមយេនឌ័រ អាយុ និងប្រភេទនៃភាពងាយរងគ្រោះ)<br>៣. អត្រាបញ្ចប់ការសិក្សានៅសាលារៀន និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ<br>៤. អត្រាកុមារដែលរាយការណ៍អំពីការផ្លាស់ប្តូរផ្អែកតាមការយល់ដឹងរបស់ពួកគេអំពីជម្រើសអាជីព ទំនុកចិត្តក្នុងការអភិវឌ្ឍអាជីព និងសមត្ថភាពធ្វើការសម្រេចចិត្ត |
| គ្រួសារ | ៥. % សមាជិក SHG ដែលដឹងពីកន្លែង និងវិធីសាស្ត្រក្នុងការរាយការណ៍អំពីការរំលោភបំពានលើការការពារ |
| ប្រព័ន្ធ | ៦. កម្រិតនៃការអនុវត្តស្តង់ដារជាតិសម្រាប់ OVC ដោយសមាជិក CCWC |

### សកម្មភាពស្នូល

មានគម្រោងជាច្រើនដែលនឹងធ្វើឱ្យ **អកកអ** បញ្ជ្រាបដល់សហគមន៍ឱ្យយល់ដឹងអំពីសិទ្ធិរបស់កុមារ និងការរំលោភបំពានកុមារ។ **អកកអ** នឹងជួយដល់អ្នកដែលទទួលខុសត្រូវចំពោះការការពារកុមារ រួមមានឪពុកម្តាយ អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការបង្ការ និងឆ្លើយតបទៅនឹងការរំលោភបំពានកុមារឱ្យបានកាន់តែល្អប្រសើរឡើង។

សកម្មភាពរួមមាន៖ ការបណ្តុះបណ្តាលអំពីសិទ្ធិកុមារ និងការការពារដល់អ្នកភូមិ និងអ្នកជាប់កាតព្វកិច្ច លើកកម្ពស់ស្តង់ដារនៃការថែទាំដែលមានលក្ខណៈល្អប្រសើរជាងមុនតាមរយៈកិច្ចខិតខំប្រឹងប្រែងទាមទារ និងភាពជាដៃគូគាំទ្រជាមួយអាជ្ញាធរមូលដ្ឋាន និងការងារផ្សេង ផ្តល់អាហារូបករណ៍អប់រំ អនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹង សម្របសម្រួលដល់ការបង្កើតសាលាកុមារមេត្រី និងមត្តេយ្យសិក្សា អនុវត្តផែនការ និងការឆ្លើយតបចំពោះការការពារសង្គមដែលសមស្រប។

## ៤.៣- ការពង្រឹងអំណាចសេដ្ឋកិច្ច

### បញ្ហា និងសិទ្ធិដែលបានដោះស្រាយ

ប្រជាជនភាគច្រើនដែលរស់នៅក្នុងតំបន់គោលដៅរបស់ **អកកអ** កំពុងតែរស់នៅក្នុងស្ថានភាពក្រីក្រលំបាក។ កត្តារួមចំណែកសំខាន់ៗរួមមានកង្វះខាតការទទួលដើមទុន និងធនធានកសិកម្ម ដីមានជីវជាតិ ការប្រែ

ប្រែប្រួលអាកាសធាតុ បញ្ហាខ្វះខាតឱកាសការងារ សមត្ថភាពបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កើនប្រាក់ចំណូលនៅមានកម្រិត កង្វះខាតប្រព័ន្ធការពារសង្គម និងឱកាសបង្កើនធនធានដែលភាគច្រើនមានតែនៅតំបន់ប្រជុំជន។ ផលប៉ះពាល់នៃភាពក្រីក្រលើកុមារមានច្រើនយ៉ាង។ ភាពក្រីក្រ និងមូលហេតុនៃភាពក្រីក្របណ្តាលឱ្យមានផលប៉ះពាល់ជាច្រើនចំពោះកុមារ និងគ្រួសាររបស់ពួកគេនៅតំបន់គោលដៅរបស់ **អកកអ** រួមមាន៖ សុខភាព និងកម្រិតអប់រំខ្សោយ កង្វះអាហារូបត្ថម្ភ ភាពងាយរងគ្រោះកាន់តែខ្លាំងឡើងចំពោះការកេងផលចំណេញ និងការរំលោភបំពាន ការចូលរួមតិចតួចក្នុងសកម្មភាពទូទៅ បញ្ហាអន្តោប្រវេសន៍ច្រើនឡើង និងសាមគ្គីភាពសង្គមនៅមានកម្រិត។

គោលដៅយុទ្ធសាស្ត្រពង្រឹងអំណាចសេដ្ឋកិច្ចត្រូវបានអនុវត្តឡើងដោយស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងជីវិត និងសុខភាព។

## គោលដៅទី ២៖ កាត់បន្ថយភាពងាយរងគ្រោះចំពោះកុមារតាមរយៈការធ្វើឱ្យប្រសើរឡើងនូវជីវភាពគ្រួសារ និងសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព

### គោលបំណង៖

២.១ បង្កើនចំនួនយុវជនវ័យក្មេងៗ និងគ្រួសារដែលទទួលបានដើមទុន និងធនធានផ្សេងៗឱ្យធ្វើសកម្មភាពបង្កើនប្រាក់ចំណូល

២.២ ពង្រីកចំណេះដឹង និងជំនាញទាក់ទងនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ/ការបង្កើនប្រាក់ចំណូល ព្រមទាំងបង្កើនកម្រិតនៃការគាំទ្រដល់យុវជនវ័យក្មេងៗ និងគ្រួសារដោយកំណត់ពីឱកាសការងារជាក់លាក់

២.៣ ធ្វើឱ្យប្រសើរឡើងនូវការទទួលបានការប្រើប្រាស់ទឹកស្អាត និងអនាម័យដើម្បីជំរុញឱ្យអ្នកភូមិធ្វើការប្រកបដោយផលិតភាព

### សកម្មភាពសំខាន់ៗ៖

២.១ បង្កើនចំនួនយុវជនវ័យក្មេងៗ និងគ្រួសារដែលមានដើមទុន និងធនធានផ្សេងៗឱ្យធ្វើសកម្មភាពបង្កើនប្រាក់ចំណូល

- ២.១.១ កែលម្អក្រុមជួយខ្លួនឯងដើម្បីងាយស្រួលផ្តល់ប្រាក់កម្ចី
- ២.១.២ ពង្រីកធនាគារសត្វ ដូចជាធនាគារគោ បន្ទាប់ពីមានការពិនិត្យផ្ទៀងផ្ទាត់ដើម្បីធានាពីភាពអាចផ្តល់ផលចំណេញនៃកម្មវិធីដែលជាប្រភពចំណូលរបស់ **អកកអ**។
- ២.១.៣ បង្កើនឱកាសសម្រាប់យុវជនវ័យក្មេង និងគ្រួសារដើម្បីទទួលបានធនធានសំខាន់ៗ ដូចជាឧបករណ៍ធ្វើកសិកម្ម ការប្រឹក្សាយោបល់បច្ចេកទេសពីអ្នកជំនាញ
- ២.១.៤ រៀបចំផែនការ និងសម្របសម្រួលដល់សកម្មភាពពង្រឹងអំណាចសេដ្ឋកិច្ចដែលគិតគូរអំពីទីផ្សារ/កម្លាំងពលកម្មឧស្សាហកម្ម និងផលប្រយោជន៍ពីឱកាសធ្វើអាជីវកម្ម

២.២ ពង្រីកចំណេះដឹង និងជំនាញទាក់ទងនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ/ការបង្កើនប្រាក់ចំណូល ព្រមទាំងបង្កើនកម្រិតនៃការគាំទ្រដល់យុវជនវ័យក្មេងៗ និងគ្រួសារ

២.២.១ បង្កើន និងបង្កើតវគ្គបណ្តុះបណ្តាលបន្ថែមទៀតសម្រាប់យុវជនវ័យក្មេងៗ និងគ្រួសារដោយសហការជាមួយអ្នកជំនាញបច្ចេកទេស អ្នករៀបចំការបណ្តុះបណ្តាល និងអាជីវកម្មពាក់ព័ន្ធ

២.២.២ បង្កើតកិច្ចសហការប្រកបដោយប្រសិទ្ធភាពក្នុងចំណោមក្រុមជួយខ្លួនឯង អ្នកជំនាញបច្ចេកទេស អ្នករៀបចំការបណ្តុះបណ្តាល និងអាជីវកម្មពាក់ព័ន្ធដើម្បីចែករំលែកជំនាញ

២.២.៣ បង្កើតឱកាសការងារសម្រាប់យុវជនវ័យក្មេងៗដោយសហការជាមួយវិស័យឯកជន ឬសហគ្រិន

២.២.៤ អភិវឌ្ឍគម្រោងផ្តួចផ្តើមកសិករគោលដើម្បីបង្កើតក្រុមផលិតដែលមានជំនាញច្បាស់លាស់ និងមានផែនការដាំដំណាំចម្រុះ និងកិច្ចសហប្រតិបត្តិការក្នុងចំណោមកសិករមូលដ្ឋានរួមមានសហគមន៍កសិកម្ម និងការកំណត់ពីទីផ្សារ និងបញ្ហាប្រឈមក្នុងការធ្វើទីផ្សារ

២.៣ ធ្វើឱ្យប្រសើរឡើងនូវការទទួលបានការប្រើប្រាស់ទឹកស្អាត និងអនាម័យដើម្បីជំរុញឱ្យអ្នកភូមិធ្វើការប្រកបដោយផលិតភាព

២.៣.១ ពង្រឹងសមត្ថភាពនៃសេវាសុខាភិបាលសំខាន់ៗ និងភាគីពាក់ព័ន្ធផ្សេងៗដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានទឹកស្អាតប្រើប្រាស់ និងអនាម័យល្អ សេវាសុខាភិបាលសមរម្យ និងព័ត៌មានសុខាភិបាល

២.៣.២ សហការជាមួយភ្នាក់ងារសុខាភិបាល/អ្នកផ្តល់សេវាពាក់ព័ន្ធផ្សេងៗ និងគាំទ្រដល់តួនាទីរបស់ពួកគេក្នុងការដឹកនាំការអនុវត្តអន្តរគមន៍ពាក់ព័ន្ធនឹងសុខាភិបាល

២.៣.៣ ចាប់ផ្តើមគម្រោងដែលដោះស្រាយតម្រូវការពាក់ព័ន្ធនឹងសុខភាពបឋមដូចជាទឹកស្អាត និងអនាម័យ អាហារូបត្ថម្ភ ក្នុងកាលៈទេសៈមួយនៃតម្រូវការដ៏សំខាន់ និងដែលមានប្រភពទឹកគ្មានសារធាតុបំពុលដោយកំបោរ និងជាតិដែក។

## លទ្ធផលដែលបានព្រាងទុក

លទ្ធផលរយៈពេលវែង៖ ភាពងាយរងគ្រោះចំពោះកុមារត្រូវបានកាត់បន្ថយតាមរយៈជីវភាពសង្គមសេដ្ឋកិច្ចដែលត្រូវបានកែលម្អ និងមាននិរន្តរភាពចំពោះគ្រួសារ និងសហគមន៍របស់ពួកគេ។

## លទ្ធផលសំខាន់ៗ៖

- ការទទួលបានដើមទុន និងធនធានផ្សេងៗបានបង្កើនចំនួនយុវជនវ័យក្មេង និងគ្រួសារដែលបានចាប់ផ្តើមសកម្មភាពបង្កើនប្រាក់ចំណូលថ្មី
- យុវជនវ័យក្មេង និងគ្រួសារទទួលបានចំណេះដឹង និងជំនាញពាក់ព័ន្ធនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ បង្កើនប្រាក់ចំណូល និងទទួលបានការគាំទ្រយ៉ាងល្អប្រសើរឱ្យអនុវត្តជាក់ស្តែង
- ការងារ និងធនធានពាក់ព័ន្ធនឹងការផ្តល់ទឹកស្អាត និងអនាម័យនឹងទទួលបានការកែលម្អដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកភូមិឱ្យធ្វើការប្រកបដោយផលិតភាព

**ភស្តុតាងនៃការផ្លាស់ប្តូរ - សូចនាករ**

| | |
|---|---|
| គោលដៅ | សូចនាកររយៈពេល ៣ ឆ្នាំ |
| កុមារ | ១. % យុវជនវ័យក្មេងដែលរាយការណ៍អំពីប្រាក់ចំណូលតាមរយៈការចាប់ផ្តើមអនុវត្តសកម្មភាពបង្កើនប្រាក់ចំណូល ដោយប្រើប្រាស់មូលនិធិ និង/ឬធនធានសម្រាប់ចាប់ផ្តើមអាជីវកម្មដំបូងដែលទទួលបាន<br>២. យុវជនវ័យក្មេងអាយុពី ១៥ ទៅ ១៧ ឆ្នាំ ដែលកំពុងតែស្វែងរកប្រាក់ចំណូលបន្ថែមតាមរយៈចំណេះដឹង ជំនាញដែលបានសិក្សា និងការគាំទ្រផ្សេងៗ |
| គ្រួសារ | ៣. % គ្រួសារដែលរាយការណ៍អំពីប្រាក់ចំណូលតាមរយៈការចាប់ផ្តើមអនុវត្តសកម្មភាពបង្កើនប្រាក់ចំណូល បានប្រើប្រាស់មូលនិធិ និង/ឬធនធានសម្រាប់ចាប់ផ្តើមអាជីវកម្មដំបូងដែលទទួលបាន<br>៤. ចំនួនគ្រួសារដែលមានអាហារហូបចុកគ្រប់គ្រាន់បានច្រើនខែជាងមុនក្នុងមួយឆ្នាំ និងដោយគ្មានជំពាក់បំណុល<br>៥. អត្រាសមាជិកគ្រួសារដែលឈប់សម្រាកពីការងារដោយសារតែជំងឺកើតចេញពីកង្វះអនាម័យ<br>៦. រយៈពេលដែលគ្រួសារសន្សំបាន ពេលមិនទៅរែកទឹក |

## សកម្មភាពស្នូល

សកម្មភាពដែលផ្តោតលើការបង្កើតប្រាក់ចំណូលនិងការងារ នឹងកើនឡើងក្នុងរយៈពេល ៤ ឆ្នាំបន្ទាប់។ នៅពេលដែលគ្រួសារកាន់តែច្រើនមានប្រាក់ចំណូលកាន់តែច្រើន នោះកុមារកាន់តែច្រើននឹងនៅបន្តការសិក្សានៅសាលារៀន។ ក៏មានផងដែរនូវឱកាសសម្រាប់យុវជនវ័យក្មេងក្នុងការចូលរួមសកម្មភាពដែលនឹងជួយពួកគេឱ្យស័ក្តិសមនឹងការងារ និង/ឬចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន។ ការទទួលបានសេវាសុខាភិបាលដ៏ល្អប្រសើរនឹងកើតមានតាមរយៈការជួយដល់អង្គការផ្សេងៗ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពក្នុងតំបន់គោលដៅរបស់ **អកកអ**។

សកម្មភាពរួមមាន៖ ក្រុមជួយខ្លួនឯង - ធនាគារគោ និងក្របី សួនដំណាំពោត និងបន្លែ កម្ចីលើគ្រាប់ពូជ ការអភិវឌ្ឍជំនាញអាជីវកម្ម ការបណ្តុះបណ្តាលអំពីការធ្វើកសិកម្ម សកម្មភាពបង្កើតប្រាក់ចំណូលក្នុងស្រុក ការបណ្តុះបណ្តាលវិជ្ជាជីវៈ ភាពជាដៃគូជាមួយវិស័យឯកជន ការកសាងសមត្ថភាពសេវាសុខាភិបាល និងស្ថាប័នផ្សេងៗ។

# ៤.៤- ការពង្រឹងអំណាចសង្គម

## បញ្ហា និងសិទ្ធិដែលបានដោះស្រាយ

សិទ្ធិចូលរួមនៅក្នុងប្រទេសកម្ពុជាមិនសូវត្រូវបានអនុវត្ត នៅពេលដែលវាមិនស្របតាមតម្លៃប្រពៃណី។ របាយការណ៍ជាទូទៅបានបង្ហាញថា កុមារមានសិទ្ធិអំណាច/ឥទ្ធិពលធ្វើការសម្រេចចិត្តតិចតួចបំផុតដែលជះ

ឥទ្ធិពលដល់ការរស់នៅរបស់ពួកគេ។ ជាទូទៅ កុមារមិនត្រូវបានណែនាំឱ្យចេះបញ្ចេញគំនិតរបស់ខ្លួនក្នុងគ្រួសារ និងក្នុងបរិស្ថានសាលារៀនឡើយ។ ការចូលរួមរបស់កុមារក្នុងសហគមន៍មានកម្រិតទាបបំផុតនៅប្រទេសកម្ពុជា។ ក្នុងចំណោមគ្រួសារក្រីក្របំផុត មានគ្រួសារមួយចំនួនតូចប៉ុណ្ណោះដែលបានចូលរួមក្នុងដំណើរការធ្វើផែនការភូមិ ឬឃុំ ដែលគ្រួសារភាគច្រើនមានការយល់ដឹង និងជំនាញទាប គ្មានសមត្ថភាព ឬទំនុកចិត្តក្នុងការចូលរួមនៅក្នុងសកម្មភាពសហគមន៍ និងដំណើរការធ្វើផែនការ។ ស្ត្រីមិនត្រូវបានគេរាប់បញ្ចូលក្នុងដំណើរការអភិវឌ្ឍន៍សហគមន៍ឡើយ។

គ្រួសារនៅតំបន់ជនបទភាគច្រើននៅប្រទេសកម្ពុជាមានការបែងចែកឋានានុក្រម និងឱ្យតម្លៃបុរសខ្ពស់ដែលសមាជិកវ័យក្មេងត្រូវគោរពចាស់ទុំ។ ការសម្រេចចិត្តសំខាន់ៗ ដូចជាអាពាហ៍ពិពាហ៍ដែលមានការរៀបចំត្រូវបានធ្វើឡើងដោយឪពុកម្តាយតាមទម្លាប់ បន្ទាប់ពីបានប្រឹក្សាយោបល់ជាមួយចាស់ទុំផ្សេងទៀតនៅក្នុងគ្រួសារ។ សញ្ញាណនៃការពង្រឹងអំណាចសង្គមដល់កុមារអាចមិនស្របតាមប្រពៃណី និងបទដ្ឋានសង្គមឡើយ ហើយអាចត្រូវបានចាត់ទុកថាជា ការមិនគោរព ឬគ្មានសីលធម៌ចំពោះចាស់ទុំ។ ការលើកទឹកចិត្តកុមារឱ្យបញ្ចេញគំនិតរបស់ខ្លួនអាចត្រូវបានចាត់ទុកថាជាការគំរាមកំហែងដល់សង្គមដែលវាធ្លាប់បានកើតឡើងកាលពីសម័យខ្មែរក្រហមដែលបានសម្លាប់សមាជិកគ្រួសាររបស់ពួកគេ។

គោលដៅយុទ្ធសាស្ត្រនៃការពង្រឹងអំណាចសង្គមត្រូវអនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិកុមារដែលទាក់ទងនឹងការចូលរួម។

### គោលដៅទី៣៖ បង្កើនចំនួនកុមារ និងគ្រួសាររបស់ពួកគេដែលត្រូវរួមចំណែកដល់ការធ្វើផែនការ និងការសម្រេចចិត្តក្នុងជីវិតរបស់ខ្លួន និងជីវិតរស់នៅរបស់អ្នកដទៃ

### គោលបំណង៖

៣.១ បង្កើនឱកាសដល់កុមារ និងគ្រួសារឱ្យចូលរួមដំណើរការធ្វើផែនការក្នុងសហគមន៍ ការសម្រេចចិត្ត និងគំនិតផ្តួចផ្តើមរបស់សហគមន៍

៣.២ បង្កើនទំនុកចិត្ត ជំនាញ និងចំណេះដឹងរបស់កុមារ និងគ្រួសារដើម្បីចូលរួមយ៉ាងសកម្មក្នុងដំណើរការធ្វើផែនការ និងការសម្រេចចិត្តក្នុងគ្រួសារ និងសហគមន៍

៣.៣ បង្កើនភាពជាប់ពាក់ព័ន្ធជាមួយសហគមន៍ និងផែនការអភិវឌ្ឍន៍របស់អាជ្ញាធរមូលដ្ឋានទៅនឹងអាទិភាពដែលបានកំណត់ក្នុងសហគមន៍ ជាពិសេសកុមារ

### សកម្មភាពសំខាន់ៗ៖

៣.១ បង្កើនឱកាសដល់កុមារ និងគ្រួសារឱ្យចូលរួមដំណើរការធ្វើផែនការក្នុងសហគមន៍ ការសម្រេចចិត្ត និងគំនិតផ្តួចផ្តើមរបស់សហគមន៍

៣.១.១ សម្របសម្រួលវេទិកាពង្រឹងអំណាចសហគមន៍ - អញ្ជើញតំណាងរដ្ឋាភិបាលឱ្យឆ្លើយតបទៅនឹងកង្វល់ និងបញ្ហារបស់សហគមន៍ក្នុងស្រុកនីមួយៗ

៣.១.២ រួមចំណែកដល់ការដាក់បញ្ចូលគំនិតរបស់កុមារ និងគ្រួសារទៅក្នុងផែនការអភិវឌ្ឍន៍ភូមិ និងផែនការវិនិយោគឃុំ

៣.១.៣ ផ្តល់ឱកាសសម្រាប់កុមារ និងយុវជនឱ្យចូលរួមយ៉ាងសកម្មក្នុងគម្រោងសហគមន៍

៣.២ បង្កើនទំនុកចិត្ត ជំនាញ និងចំណេះដឹងរបស់កុមារ និងគ្រួសារដើម្បីចូលរួមយ៉ាងសកម្មក្នុងដំណើរការធ្វើផែនការ និងការសម្រេចចិត្តក្នុងគ្រួសារ និងសហគមន៍

៣.២.១ ពង្រឹងការអនុវត្តកម្មវិធីសិក្សា និងអភិវឌ្ឍន៍ចំពោះក្រុមជួយខ្លួនឯងពាក់ព័ន្ធនឹងការធ្វើផែនការការវិភាគពីភាពក្រីក្រ និងភាពជាអ្នកដឹកនាំ

៣.២.២ ពង្រីកជំនាញ និងទំនុកចិត្តរបស់កុមារតាមរយៈការប្រឹក្សាយោបល់ជាមួយកុមារ ក្លឹបកុមារ និងគំនិតផ្តួចផ្តើមផ្សេងទៀត

៣.៣ បង្កើនភាពជាប់ពាក់ព័ន្ធជាមួយសហគមន៍ និងផែនការអភិវឌ្ឍន៍របស់អាជ្ញាធរមូលដ្ឋានទៅនឹងអាទិភាពដែលបានកំណត់ក្នុងសហគមន៍ ជាពិសេសកុមារ

៣.៣.១ ទាមទារ និងកសាងចំណេះដឹង និងជំនាញដល់អាជ្ញាធរមូលដ្ឋានដើម្បីឱ្យមានការចូលរួមពីសហគមន៍ កុមារ និងយុវជនក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍

៣.៣.២ សហការជាមួយអាជ្ញាធរមូលដ្ឋាន បង្កើត និងសាកល្បងដំណើរការធ្វើផែនការ និងការសម្រេចចិត្តដែលដាក់បញ្ចូលទាំងការចូលរួមរបស់កុមារ និងគ្រួសាររបស់ពួកគេ

## លទ្ធផលដែលបានព្រាងទុក

លទ្ធផលរយៈពេលវែង – កុមារ និងគ្រួសារកាន់តែច្រើនកំពុងតែរួមចំណែកដល់ការធ្វើផែនការ និងការសម្រេចចិត្តក្នុងឆាកជីវិតរបស់ពួកគេ និងជីវិតរបស់អ្នកដទៃ។

## លទ្ធផលរយៈពេលមធ្យម

- កុមារ និងគ្រួសារជាច្រើននាក់មានឱកាសច្រើនដើម្បីចូលរួមផ្តួចផ្តើមគំនិតក្នុងការធ្វើផែនការ អភិវឌ្ឍន៍សហគមន៍របស់ពួកគេ
- កុមារ និងគ្រួសារមានទំនុកចិត្ត និងសមត្ថភាពខ្លាំងជាងមុនក្នុងការរួមចំណែកដល់ការធ្វើផែនការ និងការសម្រេចចិត្តក្នុងគ្រួសារ និងសហគមន៍
- ផែនការអភិវឌ្ឍន៍សហគមន៍ និងអាជ្ញាធរមូលដ្ឋានត្រូវជាប់ពាក់ព័ន្ធនឹងអាទិភាពរបស់សហគមន៍ដែលបានកំណត់ ជាពិសេសកុមារ

### ភស្តុតាងនៃការផ្លាស់ប្តូរ - សូចនាករ

| គោលដៅ | សូចនាកររយៈពេល ៣ ឆ្នាំ |
|---|---|
| កុមារ | ១. # កុមារដែលចូលរួមក្នុង # និងប្រភេទនៃសកម្មភាពជាក់ស្តែងពាក់ព័ន្ធនឹងការធ្វើផែនការមូលដ្ឋាន និងការសម្រេចចិត្ត និងគំនិតផ្តួតផ្តើមសហគមន៍ (កម្រិតនៃភាពក្រីក្រខុសគ្នា អាយុ យែនឌ័រ |

| | |
|---|---|
| | អ្នករៀបចំសកម្មភាព សកម្មភាពជាក់លាក់ចំពោះកុមារ)<br>២. # ចំនួនលើកក្នុងរយៈពេល ៦ ខែចុងក្រោយដែលកុមារម្នាក់ៗបានរួមចំណែកដល់ដំណើរការធ្វើផែនការ/សម្រេចចិត្តក្នុងគ្រួសារ និងសហគមន៍ (យែនឌ័រ អាយុខុសគ្នា) |
| គ្រួសារ | ៣. # សមាជិកគ្រួសារជាយុវជនដែលចូលរួមក្នុង # និងប្រភេទនៃសកម្មភាពជាក់ស្តែងពាក់ព័ន្ធនឹងការធ្វើផែនការមូលដ្ឋាន ការសម្រេចចិត្ត និងគំនិតផ្តួចផ្តើមក្នុងសហគមន៍ (កម្រិតនៃភាពក្រីក្រខុសគ្នា អាយុ យែនឌ័រ អ្នករៀបចំសកម្មភាព)<br>៤. # យុវជនដែលកាលពី ៦ ខែមុនបានដាក់បញ្ចូលកុមារក្នុងដំណើរការធ្វើផែនការ/សម្រេចចិត្តក្នុងគ្រួសារ និងសហគមន៍ (យែនឌ័រ អាយុខុសគ្នា) |
| ប្រព័ន្ធ | ៥. % នៃអាទិភាពចំពោះសហគមន៍ដែលមាននៅក្នុង ផែនការអភិវឌ្ឍន៍ភូមិ(VDP) និង ត្រូវបានដាក់បញ្ចូលទៅក្នុង ផែនការវិនិយោគឃុំ(CIP)<br>៦. % អាទិភាពដែលបានកំណត់ជាផ្លូវការដោយក្លឹប/ក្រុមប្រឹក្សាកុមារ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការសាលារៀន CCWC និង/ឬ CIP |

### សកម្មភាពស្នូល

កុមារ និងគ្រួសារពួកគេនឹងកាន់តែមានជំនាញ ទំនុកចិត្ត និងឱកាសបន្ថែមទៀតក្នុងការបញ្ចេញមតិលើអ្វីដែលជះឥទ្ធិពលដល់ជីវិតរបស់ពួកគេ។ អាជ្ញាធរ និងភ្នាក់ងារមូលដ្ឋាននឹងផ្តល់ឱកាសដល់សហគមន៍ឱ្យចែករំលែកពីអាទិភាពរបស់ខ្លួន និងជួយផ្តល់ដំណោះស្រាយដ៏ល្អៗ។

សកម្មភាពរួមមាន៖ ការពង្រឹងសិទ្ធិអំណាច និងការកៀរគរសហគមន៍ដែលជួបហានិភ័យ ការចូលរួមរបស់កុមារនិងគ្រួសារក្នុងការសម្រេចចិត្តមូលដ្ឋាន ការបណ្តុះបណ្តាលកុមារ គ្រួសារ និងអាជ្ញាធរមូលដ្ឋានស្តីពីដំណើរការធ្វើផែនការដែលមានការចូលរួម ការគាំទ្រដល់ការរួមបញ្ចូលបន្ថែមទៀតក្នុងដំណើរការអភិវឌ្ឍន៍ដោយអ្នកភូមិ។

## ៤.៥- សមត្ថភាពរបស់ អកកអ

### បញ្ហាដែលបានដោះស្រាយ

បញ្ហាប្រឈម/ហានិភ័យ និងអនុសាសន៍សំខាន់ៗដែលត្រូវបានកំណត់ចំពោះសមត្ថភាពរបស់ **អកកអ** មានដូចតទៅ៖

- កសាងនិរន្តរភាពក្នុងការស្វែងរកមូលនិធិទាំងពីរប្រភពគឺពីម្ចាស់ជំនួយ និងសហគ្រិនសង្គមរបស់ **អកកអ**
- ធានាថា គោលនយោបាយ និងនីតិវិធីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (២០១៥)

- ធានាថា រាល់គ្រប់លក្ខខណ្ឌខាងក្រៅ និងខាងក្នុងទាំងអស់ត្រូវបានបំពេញឡើងជាមួយមូលនិធិរបស់ម្ចាស់ជំនួយ និងចំណូលចេញពីសហគ្រិនសង្គម
- ធានាថា សមត្ថភាពរបស់បុគ្គលិក **អកកអ** អាចឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវ និងតម្រូវការរបស់សហគមន៍ដែលពួកគេកំពុងបំពេញការងារ
- បង្កើតយុទ្ធសាស្ត្រដើម្បីធានាថា ភាពជោគជ័យរបស់បុគ្គលិកត្រូវបានទទួលស្គាល់ និងអបអរសាទរ
- ពិនិត្យសាជាថ្មីលើរចនាសម្ព័ន្ធរបស់ **អកកអ** ដើម្បីធានាថា តំណែង (ដូចជាមន្ត្រីហិរញ្ញវត្ថុប្រចាំស្រុក) ឆ្លើយតបទៅនឹងតម្រូវការរបស់ **អកកអ** និងសហគមន៍ដែលខ្លួនធ្វើការ
- សហការជាមួយបុគ្គលិក សហគ្រាសផលិតទឹកបរិសុទ្ធរបស់**អកកអ**(Eco-water )ដើម្បីបង្កើនលទ្ធភាពស្វែងរកប្រាក់ចំណេញ និងការរួមបញ្ចូលជាអតិបរមាទៅក្នុងដំណើរការគ្រប់គ្រងរបស់ **អកកអ** និងដើម្បីបង្កើនកេរ្តិ៍ឈ្មោះ និងផ្សាយចេញជាសាធារណៈទៅដល់សហគមន៍
- កែសម្រួលសេចក្តីពណ៌នាអំពីការងារដើម្បីធានាថា រាល់ការកែសម្រួលផ្នែកណាមួយនៃរចនាសម្ព័ន្ធត្រូវស្របតាមការពណ៌នាការងារដែលត្រឹមត្រូវ
- បង្កើតផែនការដើម្បីទាក់ទាញ និងរក្សាបុគ្គលិកមានជំនាញ
- បង្កើតយុទ្ធសាស្ត្រសម្រាប់ទំនាក់ទំនងខាងក្នុង និងខាងក្រៅប្រកបដោយប្រសិទ្ធភាព
- ពិនិត្យសាឡើងវិញលើគោលនយោបាយស្តីពីការរក្សាការសម្ងាត់របស់បុគ្គលិកពេលជ្រើសរើសបុគ្គលិក និងធានាថា គ្រប់បុគ្គលិកថ្មីនាពេលបច្ចុប្បន្ននេះយល់ដឹងអំពីលក្ខខណ្ឌទាំងនោះ
- បង្កើតប្រតិទិនប្រចាំឆ្នាំដែលមានកាលបរិច្ឆេទគោលដៅគន្លឹះដើម្បីឆ្លើយតបទៅនឹងម្ចាស់ជំនួយ និងលក្ខខណ្ឌតម្រូវខាងក្នុង
- បង្កើតសូចនាករសំខាន់ៗដើម្បីធានាពីប្រសិទ្ធភាពការងាររបស់ **អកកអ**
- រៀបចំប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ

**គោលដៅទី ៤៖ កសាងសមត្ថភាពរបស់ អកកអ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនាពេលអនាគត**

**គោលបំណង៖**

៤.១ រៀបចំ **អកកអ** ឱ្យមានមូលនិធិដោយខ្លួនឯងគ្រប់គ្រាន់រយៈពេលវែង

៤.២ បង្កើនកម្រិតនៃការផ្តល់មូលនិធិរបស់ **អកកអ** និងកែលម្អការរៀបចំមូលនិធិក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍស្ថាប័ន

៤.៣ ពង្រឹងគុណភាពការងារ

៤.៤ បន្តកសាងសមត្ថភាព និងការងារក្រុមក្នុងចំណោមថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រង

៤.៥ ទាក់ទាញ បង្កើត និងរក្សាក្រុមដែលមានសមត្ថភាព និងចម្រុះ

៤.៦ ពិនិត្យសាឡើងវិញលើប្រព័ន្ធហិរញ្ញវត្ថុរបស់ **អកកអ**

៤.៧ ពិនិត្យសាឡើងវិញលើរចនាសម្ព័ន្ធរបស់ **អកកអ**

៤.៨ បង្កើតអភិក្រមគ្រប់គ្រងតាមករណីសិក្សា

៤.៩ អនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ

៤.១០ លើកកម្ពស់ការថែទាំ និងសុខុមាលភាពរបស់បុគ្គលិក

៤.១១ ពិនិត្យឡើងវិញនូវការពណ៌នាអំពីតួនាទីរបស់ **អកកអ** ដើម្បីឱ្យស្របទៅនឹងការផ្លាស់ប្តូរលើការយកចិត្តទុកដាក់ និងរចនាសម្ព័ន្ធរបស់ស្ថាប័ន

៤.១២ បណ្តុះបណ្តាលបុគ្គលិកថ្មីអំពីគោលនយោបាយធនធានមនុស្ស ដូចជាតម្រូវការសម្រាប់ការរក្សាការសម្ងាត់

៤.១៣ រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់ការទាក់ទងខាងក្នុង និងខាងក្រៅ

៤.១៤ រៀបចំផែនការដើម្បីអបអរសាទរដល់សមិទ្ធផលរបស់បុគ្គលិក **អកកអ**

## សកម្មភាពសំខាន់ៗ៖

៤.១ រៀបចំ **អកកអ** ឱ្យមានមូលនិធិដោយខ្លួនឯងគ្រប់គ្រាន់រយៈពេលវែងតាមរយៈការធ្វើផែនការដោយប្រុងប្រយ័ត្ន ដូចជាភាពអាចផ្តល់ប្រាក់ចំណេញខាងហិរញ្ញវត្ថុ និងផលប៉ះពាល់លើសកម្មភាពផ្សេងៗរបស់ **អកកអ**

៤.១.១ រៀបចំផែនការគ្រប់ជ្រុងជ្រោយ (រួមមានថវិកា) សម្រាប់ការសាងសង់សាលាភាសាអង់គ្លេសលើដីរបស់ **អកកអ** នៅស្រុកវាលវែង

៤.១.២ ពិនិត្យឡើង និងបន្តអភិវឌ្ឍ Eco-Water

៤.១.៣ បង្កើតសហគ្រិនសង្គមធនាគារគោលើដីរបស់ **អកកអ** នៅក្នុងស្រុកវាលវែង

៤.២ បង្កើនកម្រិតនៃការផ្តល់មូលនិធិរបស់ អកកអ និងកែលម្អការរៀបចំមូលនិធិក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍស្ថាប័នតាមរយៈនាយកប្រតិបត្តិដែលអាទិភាពក្នុងកាតព្វកិច្ចរបស់គាត់គឺស្វែងរកមូលនិធិសប្បុរសជនបន្ថែម

៤.២.១ ក្រុមប្រឹក្សា និងគណៈគ្រប់គ្រងត្រូវរក្សាភាពជាដៃគូជាមួយម្ចាស់ជំនួយដែលមានស្រាប់ និងទាក់ទងស្វែងរកម្ចាស់ជំនួយថ្មី។ សមាជិកក្រុមប្រឹក្សាដែលមានជំនាញខាងអាជីវកម្មត្រូវបានជ្រើសរើស។

៤.២.២ បង្កើត និងអនុវត្តផែនការរៃអង្គាសប្រាក់ និងធនធានដ៏រឹងមាំដើម្បីផ្តល់មូលនិធិដល់ការអនុវត្តផែនការយុទ្ធសាស្ត្រឱ្យបានគ្រប់គ្រាន់

៤.២.៣ ពិនិត្យចរចាសាឡើងវិញលើកិច្ចសន្យាផ្តល់មូលនិធិដើម្បីរ៉ាប់រងលើការចំណាយផ្នែករដ្ឋបាល និងចំណាយលើការពិនិត្យតាមដាន/វាយតម្លៃរបស់ស្ថាប័ន

៤.២.៤ រៀបចំផែនការក្នុងការកំណត់ម្ចាស់ជំនួយថ្មី និងដំណើរការអនុវត្តជំនួយឥតសំណងថ្មី

៤.២.៥ ពិនិត្យផ្ទៀងផ្ទាត់ប្រព័ន្ធហិរញ្ញវត្ថុ គោលនយោបាយ និងដំណើរការដើម្បីធានាពីប្រសិទ្ធភាព ប្រសិទ្ធផល និងតម្លាភាព

៤.២.៦ ធានាថា ប្រព័ន្ធ គោលនយោបាយ ដំណើរការ និងការរាយការណ៍គឺឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវ ដោយធានាថា គោលនយោបាយ និងនីតិវិធីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (២០១៥)

៤.៣ ពង្រឹងគុណភាពការងារ

៤.៣.១ អនុវត្តក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃដែលមានគុណភាពខ្ពស់ និងមូលនិធិគ្រប់គ្រាន់ ដូចជា វិធីសាស្ត្រដែលបានកែលម្អ

៤.៣.២ ធានាថា រាល់គ្រប់លក្ខខណ្ឌតម្រូវផ្នែកសវនកម្មខាងក្នុង និងខាងក្រៅទាំងអស់ត្រូវបានបំពេញឡើង (សម្រាប់មូលនិធិរបស់ម្ចាស់ជំនួយ និងសហគ្រិនសង្គម) និងចាត់តាំងមន្ត្រីម្នាក់ដែលទទួលខុសត្រូវចំពោះការពិនិត្យដំណើរការសវនកម្ម

៤.៣.៣ ទទួលបានការទទួលស្គាល់គុណភាពដោយមានប្រព័ន្ធបញ្ជាក់ពីគម្រោងដែលមានបទពិសោធន៍ល្អរបស់អង្គការមិនមែនរដ្ឋាភិបាល (NGOGPP)

៤.៣.៤ កត់ត្រាទុក និងផ្សព្វផ្សាយពីបទពិសោធន៍ល្អៗ

៤.៣.៥ បង្កើតភាពជាដៃគូថ្មី និងពង្រឹងភាពជាដៃគូដែលមានស្រាប់ជាមួយភាគីពាក់ព័ន្ធ

៤.៣.៦ បង្កើត និងរក្សាតារាងពេលវេលានៃកាលបរិច្ឆេទគោលដៅសំខាន់ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវរបស់ម្ចាស់ជំនួយ និងលក្ខខណ្ឌធ្វើផែនការផ្ទៃក្នុង

៤.៣.៧ ធ្វើផែនការ និងអនុវត្តប្រព័ន្ធគ្រប់គ្រងតាមករណីសម្រាប់ការធ្វើផែនការ អនុវត្ត និងពិនិត្យតាមដានលើការផ្តល់សេវាដល់សហគមន៍នានាដោយ **អកកអ**

៤.៣.៨ ធានាថា រាល់គ្រប់អណ្តូងទឹកដែលបានសាងសង់រួចត្រូវបានពិនិត្យពីកម្រិតជាតិដែក និងកំបោរ ហើយថា រាល់អណ្តូងណាដែលមានជាតិពុលត្រូវមានយុទ្ធសាស្ត្រជាមុនចំពោះការធ្វើប្រព្រឹត្តកម្មទឹក (ចម្រោះ) ហើយថា ត្រូវស្វែងរកមូលនិធិដើម្បីអនុវត្តការងារនេះ

៤.៤ បង្កើតក្រុមការងារដែលមានសមត្ថភាព និងចម្រុះ

៤.៤.១ បង្កើតកម្រិតប្រាក់បៀវត្សរ៍បុគ្គលិកថ្មី

៤.៤.២ កសាងមូលដ្ឋានក្រុមស្ម័គ្រចិត្តធំជាងមុនដោយមានអ្នកស្ម័គ្រចិត្តជាតិ និងអន្តរជាតិ

៤.៤.៣ ពង្រឹងកម្មវិធីសិក្សា និងអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ បុគ្គលិក និងអ្នកស្ម័គ្រចិត្ត

៤.៤.៤ ពិនិត្យផ្ទៀងផ្ទាត់ និងអនុវត្តតួនាទី និងរចនាសម្ព័ន្ធដែលបានកែសម្រួលរបស់ស្ថាប័ន រួមមាន អនុសាសន៍ដែលមន្ត្រីហិរញ្ញវត្ថុត្រូវបានចាត់តាំងដល់ការិយាល័យស្រុក

## លទ្ធផលដែលបានព្រាងទុក

លទ្ធផលរយៈពេលវែង - សមត្ថភាពរបស់ **អកកអ** ដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមនាពេលអនាគតត្រូវបានកសាងឡើង។

## លទ្ធផលសំខាន់ –

- **អកកអ** ត្រូវបានរៀបចំឡើងឱ្យពឹងផ្អែកលើខ្លួនឯងក្នុងរយៈពេលវែង

- ចំណូលរបស់ **អកកអ** ត្រូវបានបង្កើនឡើង ហើយការរៀបចំមូលនិធិបានជំរុញដល់ការអភិវឌ្ឍរបស់ស្ថាប័ននេះយ៉ាងល្អប្រសើរ
- គុណភាពការងារត្រូវបានកែលម្អ
- **អកកអ** នឹងមានក្រុមការងារដែលមានសមត្ថភាព និងចម្រុះ

**ភ័ស្តុតាងនៃការផ្លាស់ប្តូរ - សូចនាករ**

| | |
|---|---|
| គោលដៅ | សូចនាកររយៈពេល ៤ ឆ្នាំ |
| មូលនិធិ/ធនធាន | ១. ការត្រៀមខ្លួនរួចជាស្រេចរបស់ **អកកអ** ក្នុងការផ្លាស់ប្តូរទៅកាន់គំរូធនធានថ្មី<br>២. ភាពគ្រប់គ្រាន់នៃការបែងចែកពេលវេលា និងធនធានដែលត្រូវអនុវត្តគម្រោង និងកម្មវិធី (ដូចដែលគណៈគ្រប់គ្រងបានកំណត់)<br>៣. ចំនួនមូលនិធិ និងធនធានដែល **អកកអ** ទទួលបាន |
| គុណភាព | ៤. កម្រិតនៃសមត្ថភាព/គុណភាពស្ថាប័នរបស់ **អកកអ** |
| សមាជិកក្រុម | ៥. ភាពចុះសម្រុងគ្នានៃសកម្មភាពស្នូលរបស់ **អកកអ** និងក្រុមការងារ<br>៦. ភាពសមរម្យនៃតួនាទីសមាជិកក្រុម និងរចនាសម្ព័ន្ធស្ថាប័ន |

**សកម្មភាពស្នូល**

តាមរយៈការស្វែងរកប្រភពរៃអង្គាសប្រាក់បន្ថែមដូចជាសហគ្រិនសង្គម **អកកអ** អាចនឹងបង្កើតប្រាក់ចំណូលបន្ថែមទៀតដើម្បីទូទាត់លើគម្រោងរយៈពេលវែង និងធ្វើឱ្យ **អកកអ** រឹងមាំជាងមុន។ ក្រុមការងារ **អកកអ** នឹងត្រូវបានពង្រឹងបន្ថែមតាមរយៈការទាក់ទាញ និងរក្សាសមាជិកក្រុមការងារដែលមានសមត្ថភាព។ **អកកអ** នឹងរក្សា ហើយកែលម្អគុណភាពការងាររបស់ខ្លួនតាមរយៈ៖ ធ្វើឱ្យប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ព្រមទាំងដំណើរការ និងវិធីសាស្ត្ររបស់ខ្លួនមានភាពល្អប្រសើរឡើង ទទួលបានការទទួលស្គាល់គុណភាពជាមួយនឹង NGO-GPP ការកត់ត្រាទុក និងចែករំលែកបទពិសោធន៍ល្អៗ បង្កើតភាពជាដៃគូថ្មី និងពង្រឹងភាពជាដៃគូដែលមានស្រាប់ជាមួយភាគីពាក់ព័ន្ធ។

សកម្មភាពរួមមាន៖ ស្វែងរកម្ចាស់ជំនួយថ្មី និងពង្រឹងទំនាក់ទំនងជាមួយម្ចាស់ជំនួយដែលមានស្រាប់ បង្កើតមូលដ្ឋានក្រុមស្ម័គ្រចិត្តធំជាងមុនដោយមានអ្នកស្ម័គ្រជាតិ និងអន្តរជាតិ កែសម្រួលតួនាទី និងរចនាសម្ព័ន្ធស្ថាប័នរបស់ **អកកអ** បណ្តុះបណ្តាល និងគាំទ្រដល់បុគ្គលិកឱ្យបន្តពង្រឹងជំនាញរបស់ខ្លួនដើម្បីឱ្យពួកគេអាចបំពេញបេសកកម្មរបស់ស្ថាប័នបាន។

## ៥- ការអនុវត្តយុទ្ធសាស្ត្រ

### ៥.១- កម្មវិធីបច្ចុប្បន្ន

ការផ្លាស់ប្តូរជាច្រើនត្រូវបានធ្វើឡើងសម្រាប់កម្មវិធីរបស់ **អកកអ** ដែលជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រនេះ។ ការអនុវត្តសំខាន់ៗរួមមាន៖

- បន្តយកចិត្តទុកដាក់ខ្លាំងជាងមុនលើសកម្មភាពពង្រឹងអំណាចសង្គម និងសេដ្ឋកិច្ចដែលត្រូវធ្វើឡើងដោយ **អកកអ**
- សកម្មភាពភាគច្រើនពាក់ព័ន្ធនឹងសុខាភិបាល ទឹកស្អាត និងអនាម័យ ការសាងសង់សាលារៀន និងការផ្គត់ផ្គង់ឧបករណ៍នឹងត្រូវបានដាក់បញ្ចូលក្រោមទិសដៅពង្រឹងអំណាចសេដ្ឋកិច្ច។
- សកម្មភាព និងយុទ្ធសាស្ត្រកម្មវិធីនឹងផ្តោតយកចិត្តទុកដាក់កាន់តែខ្លាំងលើលទ្ធផលចំពោះកុមារជាពិសេស
- អង្គការនឹងសិក្សាបន្ថែមអំពីអភិក្រមគ្រប់គ្រងតាមករណីសិក្សា

### ការការពារ និងការអភិវឌ្ឍកុមារ

ចាប់តាំងពី **អកកអ** ត្រូវបានបង្កើតឡើង **អកកអ** បានកំពុងតែបង្កើតសកម្មភាពដែលពាក់ព័ន្ធនឹងការការពារ និងការអភិវឌ្ឍកុមារ។ កាលពីមុន ការងារនេះគឺស្ថិតក្រោមប្រភេទការងារមិនច្បាស់លាស់នៃវិស័យអប់រំ និងការប្រឆាំងការជួញដូរកុមារ/ការលើកកម្ពស់សិទ្ធិកុមារ។ ដំណើរការធ្វើផែនការយុទ្ធសាស្ត្របានជួយដល់ការស្វែងយល់ពីអាទិភាពសំខាន់ៗរបស់ស្ថាប័នចំពោះកុមារនៅក្នុងតំបន់គោលដៅរបស់ **អកកអ**។ សកម្មភាពនេះបណ្តាលឱ្យមានការប្តេជ្ញាចិត្តក្នុងការបង្កើតអភិក្រមយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាការពារកុមារ និងតម្រូវការអភិវឌ្ឍន៍កុមារដែលងាយរងគ្រោះ។ ជាលទ្ធផល **អកកអ** នឹងបន្តបង្កើតអន្តរាគមន៍ពាក់ព័ន្ធនឹងគោលដៅដែលធានាថា កុមារត្រូវទទួលបានការអប់រំ ការការពារ និងការថែទាំ។

### ការពង្រឹងអំណាចសេដ្ឋកិច្ច

សកម្មភាពពាក់ព័ន្ធនឹងការកែលម្អជីវភាពរស់នៅ និងសុវត្ថិភាពចំណីអាហារគឺជាសមាសធាតុស្នូលនៃគម្រោងដែលបានធ្វើឡើងដោយ **អកកអ**។ តាមរយៈការទទួលស្គាល់ភាពជោគជ័យរបស់ខ្លួន **អកកអ** មានគោលបំណងបន្តពង្រីកការងារនេះដើម្បីរួមចំណែកដល់ការផ្លាស់ប្តូរប្រកបដោយនិរន្តរភាពរយៈពេលវែងចំពោះគ្រួសារដែលងាយរងគ្រោះ។ រយៈពេលបីឆ្នាំក្រោយ នឹងមានការពង្រីកសកម្មភាពពាក់ព័ន្ធនឹងការផ្តល់ប្រាក់កម្ចីការបង្កើតប្រាក់ចំណូល និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ឱកាសបន្ថែមនឹងត្រូវបានផ្តល់ឱ្យយុវជនវ័យក្មេងដើម្បីទទួលបានចំណេះដឹង និងជំនាញចាំបាច់ក្នុងគោលបំណងស្វែងរកការងារមួយដែលសមស្រប និង/ឬចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន។ សកម្មភាពពាក់ព័ន្ធនឹងសុខាភិបាល ទឹកស្អាត និងអនាម័យនឹងមានលក្ខណៈជាបណ្តាញតភ្ជាប់ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកភូមិឱ្យធ្វើការងារដោយមានផលិតភាពខ្ពស់។

### ការពង្រឹងអំណាចសង្គម

តាមរយៈក្រុមជួយខ្លួនឯង **អកកអ** បានជំរុញឱ្យអ្នកភូមិរួមចំណែកដល់ដំណើរការធ្វើផែនការភូមិ/ឃុំ និងគំនិតផ្តួចផ្តើមរបស់សហគមន៍។ ក្នុងរយៈពេលបួនឆ្នាំបន្ទាប់ កិច្ចខិតខំប្រឹងប្រែងនេះនឹងបន្តកើនឡើងគួរឱ្យកត់សម្គាល់។ អង្គការនឹងបន្តយកចិត្តទុកដាក់បន្ថែមទៀតលើកុមារដែលត្រូវចូលរួមក្នុងដំណើរការធ្វើការសម្រេចចិត្ត ក៏ដូចជាគម្រោងសហគមន៍។ **អកកអ** នឹងបន្តគាំទ្រដល់អាជ្ញាធរមូលដ្ឋានឱ្យបង្កើតដំណើរការដែលរួមបញ្ចូលទាំងកុមារងាយរងគ្រោះ និងគ្រួសារក្នុងការអភិវឌ្ឍសហគមន៍។

### សុខភាព ទឹកស្អាត និងអនាម័យ

ចាប់តាំងពីអង្គការត្រូវបានបង្កើតឡើង **អកកអ** បានវិនិយោគធនធានយ៉ាងច្រើនលើសកម្មភាពសុខាភិបាល ទឹកស្អាត និងអនាម័យ។ ក្នុងរយៈពេលបីឆ្នាំបន្ទាប់ **អកកអ** នឹងខិតខំលើកទឹកចិត្តដៃគូក្នុងស្រុកឱ្យធ្វើការបន្ថែមលើបញ្ហាទឹកស្អាត និងអនាម័យ។ នៅពេលដែលមិនមានដៃគូសមស្រប តែបែរជាមានតម្រូវការជាក់ស្តែងនោះ **អកកអ** នឹងបន្តធ្វើការលើគម្រោងទឹកស្អាត និងអនាម័យនៅសាលារៀន និងសហគមន៍។

### ការអប់រំ

**អកកអ** បានធ្វើសកម្មភាពជាច្រើនពាក់ព័ន្ធនឹងវិស័យអប់រំ។ នៅឆ្នាំបន្ទាប់ **អកកអ** នឹងផ្លាស់ប្តូរគោលដៅយកចិត្តទុកដាក់របស់ខ្លួន។ ពាក់ព័ន្ធនឹងការសាងសង់សាលារៀន និងការផ្តល់សម្ភារសិក្សា **អកកអ** នឹងពិនិត្យសាឡើងវិញនូវកម្មវិធីផ្តល់អាហារូបករណ៍ សហការជាមួយភាគីពាក់ព័ន្ធផ្សេងទៀត និងសម្របសម្រួលដល់ការបង្កើតសាលាកុមារមេត្រី និងមត្តេយ្យសិក្សា។ ការអប់រំនឹងក្លាយជាគោលបំណងដែលគាំទ្រដល់គោលដៅយុទ្ធសាស្ត្រការពារ និងអភិវឌ្ឍន៍កុមារ។

### ការប្រែប្រួលនៃការអនុវត្តថ្នាក់ស្រុក

ដោយសារតែស្ថានភាពពិសេសក្នុងស្រុកនីមួយៗដែល **អកកអ** កំពុងតែប្រតិបត្តិការ បណ្តុំសកម្មភាពដែលបានអនុវត្តក្នុងតំបន់នីមួយៗនឹងមានភាពខុសប្លែកគ្នាពីស្រុកមួយទៅស្រុកមួយ។ ផែនការអនុវត្តន៍ថ្នាក់ស្រុកនឹងត្រូវបានរៀបចំឡើងមុនបំណាច់ឆ្នាំ២០១៨។

### ជាទូទៅ៖

ក្នុងរយៈពេលបួនឆ្នាំបន្ទាប់ គេនឹងបន្តផ្តោតយកចិត្តទុកដាក់លើការកសាងទំនាក់ទំនងជាមួយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអាជីវកម្មផ្សេងទៀតដើម្បីចែករំលែកការទទួលខុសត្រូវចំពោះកុមារដែលងាយរងគ្រោះ។

**អកកអ** ត្រូវបានបង្កើតឡើងដោយមានគោលបំណងចម្បងក្នុងការធ្វើឱ្យជីវិតកុមារមានភាពល្អប្រសើរឡើង។ រហូតមកដល់ពេលបច្ចុប្បន្ននេះ អង្គការបានផ្តោតលើការងារជាច្រើនដោយធ្វើការជាមួយឪពុកម្តាយ/

គ្រួសារដើម្បីកសាងសមត្ថភាពរបស់ពួកគេក្នុងការថែទាំ និងការពារកុមារ។ **អកកអ** បង្កើនការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងក្នុងការរៀបចំកម្មវិធីដែលផ្តោតលើការធ្វើឱ្យល្អប្រសើរឡើងជាពិសេសចំពោះកុមារ និងយកចិត្តទុកដាក់លើការតាមដាន និងវាយតម្លៃរាល់ការផ្លាស់ប្តូរទាំងនោះ។ សកម្មភាពភាគច្រើនដែលផ្តោតលើកុមារផ្ទាល់ក៏នឹងកើនឡើងផងដែរ។

## ៥.២- ការអភិវឌ្ឍស្ថាប័ន

ដំណើរការធ្វើផែនការយុទ្ធសាស្ត្របានគូសបញ្ជាក់យ៉ាងច្បាស់អំពីតម្រូវការរបស់ **អកកអ** ក្នុងការធានាថា អង្គការមួយនេះបានផ្តោតយកចិត្តទុកដាក់លើការអភិវឌ្ឍស្ថាប័ន ជាពិសេសតាមរយៈការផ្លាស់ប្តូរក្នុងការជ្រើសរើសបុគ្គលិក។ ផ្នែកមួយនៃផែនការនេះ នឹងបន្តយកចិត្តទុកដាក់លើការអភិវឌ្ឍស្ថាប័នពាក់ព័ន្ធនឹង៖ ការអភិវឌ្ឍបុគ្គលិក និងភាពជាអ្នកដឹកនាំ ការពិនិត្យតាមដាន និងវាយតម្លៃ។ នេះគឺជាសមាសធាតុដ៏សំខាន់មួយនៃការបន្តពង្រឹងសមត្ថភាពរបស់ **អកកអ**។

ជាពិសេស គំនិតផ្តួចផ្តើមជាច្រើនត្រូវបានអនុវត្តឡើងដើម្បីអភិវឌ្ឍស្ថាប័នដូចជា៖ រចនាសម្ព័ន្ធរបស់ **អកកអ** នឹងត្រូវបានពិនិត្យផ្ទៀងផ្ទាត់ឡើងវិញដើម្បីឆ្លើយតបទៅនឹងកំណើនជាបន្តបន្ទាប់របស់ស្ថាប័ន តួនាទីបុគ្គលិកមួយចំនួននឹងមានការផ្លាស់ប្តូរ កម្មវិធីអភិវឌ្ឍន៍បុគ្គលិកនឹងត្រូវបានបង្កើតឡើង និងអនុវត្តដើម្បីពង្រឹងសមត្ថភាពរបស់បុគ្គលិក ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនឹងត្រូវបានបន្តពង្រឹងបន្ថែមទៀតជាមួយនឹងក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃដែលទើបតែបានបង្កើតថ្មីដើម្បីឆ្លុះបញ្ចាំងពីទិសដៅយុទ្ធសាស្ត្រ។

## ៥.៣- ការផ្តល់មូលនិធិ និងធនធាន

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រឱ្យបានពេញលេញទៅបាន កម្រិតនៃការផ្តល់មូលនិធិនឹងត្រូវបានប្តូរទិសដៅឆ្ពោះទៅកាន់សកម្មភាពដែលបានស្នើសុំ និង/ឬលើកឡើង។ ក្នុងដំណាក់កាលរៀបចំដំបូងនៃផែនការថ្មីនេះ ផែនការផ្តល់មូលនិធិ និងធនធាននឹងត្រូវបានបង្កើតឡើង និងអនុវត្តដើម្បីធានាពីភាពជោគជ័យនៃផែនការនេះ។

## ៥.៤- ភាពជាដៃគូយុទ្ធសាស្ត្រ

ផ្នែកដ៏សំខាន់នៃអភិក្រមរបស់ **អកកអ** គឺជាទំនាក់ទំនង និងភាពជាដៃគូប្រកបដោយប្រសិទ្ធភាពជាមួយភាគីពាក់ព័ន្ធសំខាន់ៗ។ នេះរួមបញ្ចូលទាំងកុមារ និងគ្រួសាររបស់ពួកគេដែល **អកកអ** ធ្វើការជាមួយម្ចាស់ជំនួយ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិផ្សេងៗ វិស័យសុខាភិបាល និងអប់រំអាជ្ញាធរមូលដ្ឋាន ព្រមទាំងមន្ទីរ-ក្រសួងចំនុះរដ្ឋាភិបាល។ **អកកអ** ប្តេជ្ញាចិត្តបន្តពង្រឹងភាពជាដៃគូដែលមានស្រាប់របស់ខ្លួន និងបង្កើតភាពជាដៃគូថ្មីដើម្បីពង្រីកការងាររបស់ខ្លួនពាក់ព័ន្ធនឹងការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់កុមារ។ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធដទៃទៀត អ្នកជាប់កាតព្វកិច្ចសំខាន់ៗនឹងអាចអនុវត្តការទទួលខុសត្រូវរបស់ខ្លួនដើម្បីលើកតម្កើងសិទ្ធិកុមារ។